ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គ.ក.ប/គ.ក.រ និង គឃ.ខប

## សម្រាប់

## ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨

(ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨)

# មាតិកា

គោលបំណង ............................................................................................................................១

I. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត និងវិធានការសន្តិសុខ....២

១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប..........................................................................................២

២. ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត ..........................................................................................៣

ក. ពេលត្រួតពិនិត្យ.....................................................................................................................៣

ខ. ក្រោយពេលត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (នៅថ្ងៃសៅរ៍ ១ ថ្ងៃមុនថ្ងៃបោះឆ្នោត)...........................៤

គ. ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត ......................................................................................៤

៣. ការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត.......................................................................................៤

៤. វិធានការសន្តិសុខ ..........................................................................................................................៥

៥. ការប្រើប្រាស់បញ្ជីបោះឆ្នោត............................................................................................................៧

៦. សិទ្ធិបោះឆ្នោត និងលក្ខខណ្ឌបោះឆ្នោត ...........................................................................................៧

ក. អ្នកមានសិទ្ធិបោះឆ្នោត.............................................................................................................. ៧

ខ. លក្ខខណ្ឌបោះឆ្នោត.................................................................................................................. ៧

II. ការប្រព្រឹត្តទៅនៃការបោះឆ្នោត..........................................................................................................៧

១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ........................................................................................................................ ៨

ក. ការរៀបចំសម្ភារ ឯកសារតាមគំរូប្លង់ .............................................................................................៨

ខ. ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ..........................................................................................................................៩

២. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ នាទីដល់ម៉ោង ៦:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត .....................១០

៣. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០ នាទីដល់ម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត.....................១១

ក. ការពិនិត្យកញ្ចប់សន្លឹកឆ្នោត.......................................................................................................... ១១

ខ. ការពិនិត្យ និងបង្ហាញត្រាសម្ងាត់....................................................................................................... ១១

៤. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត........................................................................................ ១២

៥. ពេលបោះឆ្នោតចាប់ពីម៉ោង ៧:០០ នាទីព្រឹកដល់ម៉ោង ៣:០០ នាទីរសៀល ..................................... ១២
៦. ការងាររបស់ប្រធានក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត ..................................... ១៦
ក. ករណីអ្នកបោះឆ្នោតមានម្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ឬរូបថត ឬទិន្នន័យមិនដូចគ្នា ............ ១៦
ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ ........................................ ១៦
គ. ករណីអ្នកបោះឆ្នោតណាម្នាក់មានបំណងសើកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេង ទៀត ឬ/និងសន្លឹកឆ្នោតលើស ពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត ........................................................................................................ ១៦
ឃ. ករណីអ្នកបោះឆ្នោតជាជនដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន ........................... ១៧
ង. ករណីអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ........... ១៧
ច. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្សនយោបាយ ........................................................................................ ១៨
ឆ. ករណីសន្លឹកឆ្នោតខូច ឬរហែកដោយអចេតនា ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយតែបានផ្លាស់ប្តូរចិត្តវិញ.............................................................................................. ១៨
ជ. ករណីមានការជំទាស់ ឬតវ៉ាពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត ..................... ១៨
ឈ.ករណីមានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត(ទោះបីនៅក្នុងការិយាល័យបោះឆ្នោតក្តី ឬកំពុងឈរជាជួរនៅក្នុងបរិវេណខាងក្នុងក្តី)............................................... ១៩
ញ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបានតទៅទៀត........................................................................................................ ១៩
ដ. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ៣:០០ នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះ ត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត.................................................២០
III. ការបិទការបោះឆ្នោត ....................................................................................២០
១. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច.........................................................................................២១
២. រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត...........................................................................២២
៣. កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់ ........................................................២២
៤. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» (មិនទាន់បិទផ្និតការសុវត្ថិភាព)..........................................២២

៨. ការរៀបចំទុកដាក់សម្ភារ ឯកសារនៅសល់ ..... ២៣

IV. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ..... ២៤

១. ការចាត់ចែងរៀបចំបន្ទប់រាប់សន្លឹកឆ្នោត ..... ២៤

២. វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី ដើម្បីចង់ដឹងថា អ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ..... ២៥

៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ..... ២៥

ក. សន្លឹកឆ្នោតបានការ ..... ២៥

ខ. សន្លឹកឆ្នោតមិនបានការ ..... ២៥

៤. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ..... ៣៣

ក. ការរៀបចំសម្ភារ ឯកសារ ..... ៣៣

ខ. ការពិនិត្យហិបឆ្នោត នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ..... ៣៤

គ. ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ..... ៣៥

ឃ. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ..... ៣៦

ង. ការកំណត់សុពលភាព និងការប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ..... ៣៦

ច. ការកំណត់សុពលភាពចុងក្រោយនូវរាល់សន្លឹកឆ្នោតមិនបានការ ..... ៣៧

៥. ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត ..... ៣៨

ក. ការបូកសរុបលទ្ធផល ..... ៣៨

ខ. រូបមន្តនៃការផ្ទៀងផ្ទាត់ ..... ៣៨

៦. ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ និងការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោងប្លាស្ទិក ..... ៣៩

ក. ការប្រើប្រាស់ ទ.១១០២ និង ទ.១១០៨ ..... ៣៩

ខ. ការវេចខ្ចប់ស្បោងប្លាស្ទិក ..... ៤០

V. ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ..... ៤០

១. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» ..... ៤១

២. ការវេចខ្ចប់ស្បោង «ខ» ..... ៤១

៣. ការវេចខ្ចប់សម្ភារ ឯកសារនៅសល់បញ្ជូនទៅ គធ.ឃប អមជាមួយស្បោង «ខ» ..... ៤៣

ក. ការរៀបចំវេចខ្ចប់កញ្ចប់សម្ភារ ឯកសារនៅសល់ ..... ៤៣

ខ. ការបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចុះហត្ថលេខាដោយប្រធាន គ.ក.រ ..................... ៤៣

VI. ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោត នៅសល់ទៅ លគធ.ខប ..................... ៤៣

១. ការបញ្ជូនស្បោង «ខ» និងកញ្ចប់ដាក់សម្ភារនៅសល់ទៅ លគធ.ខប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ..... ៤៣

២. ការប្រគល់ ទទួលនៅ លគធ.ខប ..................... ៤៣

ក. ពេលត្រួតពិនិត្យ ..................... ៤៣

ខ. ក្រោយពេលត្រួតពិនិត្យ ..................... ៤៤

VII. ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គធ.ខប... ៤៤

១. ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ............ ៤៤

ក. រយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ..................... ៤៤

ខ. ព័ត៌មានចាំបាច់មួយចំនួនក្នុងពាក្យបណ្តឹង ..................... ៤៥

គ. ពាក្យបណ្តឹងដាក់ក្រោយរយៈពេលកំណត់ ..................... ៤៥

ឃ. ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ ..................... ៤៦

ង. ពាក្យបណ្តឹងដែលបានដាក់ក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ ..................... ៤៧

ច. ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ដែល គធ.ខប អាចបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ..................... ៤៧

២. ការដោះស្រាយរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ..................... ៤៨

ក. ករណី គធ.ខប សម្រេចបដិសេធពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ..................... ៤៨

ខ. ករណី គធ.ខប សម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ..................... ៤៩

VIII. កិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..................... ៥០

១. សមាសភាពនៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..................... ៥០

២. បន្ទប់សម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..................... ៥០

៣. កិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..................... ៥០

ក. សម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទសម្រាប់ក្រុមត្រួតពិនិត្យ ..................... ៥១

ខ. ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលក្នុងករណីគ្មានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ដែលបានដាក់ក្រោយរយៈពេលកំណត់ ឬមានពាក្យបណ្តឹងតវ៉ា

និងពាក្យបណ្ដឹងជំទាស់ ដែលគ្មានតស្ដុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះទេ ........ ៥១
គ. ការត្រួតពិនិត្យ និងបូកសរុបលទ្ធផល ក្នុងករណី គធ.ខប សម្រេចយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យណាមួយ និងលើកសំណើទៅ គ.ជ.ប សុំព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ........ ៥៣
ឃ. ការប្រើប្រាស់ ទ.១១១០ ទ.១១១១ និងក្រដាសលទ្ធផល(ទ.១១១៨) ........ ៥៤
IX. ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោត ទៅ គ.ជ.ប ..... ៥៥
១. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» ........ ៥៥
ក. សម្ភារ ឯកសារដាក់ក្នុងកញ្ចប់ «ឃ ពិសេស» មាន៖ ........ ៥៥
ខ. ការបំពេញ ទ.១១០៧ ........ ៥៦
គ. ការផ្ទៀងផ្ទាត់ និងការបិទត្រាកញ្ចប់ «ឃ ពិសេស» និងសរសេរសម្គាល់ ........ ៥៦
២. ការវេចខ្ចប់ស្បោង «ឃ» ព្យួរលទ្ធផលជាបណ្ដោះអាសន្ន ........ ៥៧
៣. ការវេចខ្ចប់ស្បោង «ឃ» យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ........ ៥៩
៤. ការវេចខ្ចប់កញ្ចប់សន្លឹកឆ្នោតបម្រុងដោយឡែក ........ ៦០
៥. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ........ ៦០
៦. ការបញ្ជូនទៅ គ.ជ.ប ........ ៦០

# អក្សរកាត់

| | |
|---|---|
| ១- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២- គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣-លេខាធិការដ្ឋាននៃគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤- ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៥- គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៦- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា | ច.ប.ព.ស |
| ៧-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ | ច.ប.ត.រ |
| ៨- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា | ប.ន.ព.ស |
| ៩- ទម្រង់បែបបទលេខ | ទ. |
| ១០- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១១- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |

# គោលបំណង

ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ប្រព្រឹត្តទៅប្រកបដោយភាពរលូន ត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គ.ជ.ប បានរៀបចំចងក្រង « សៀវភៅណែនាំ គ.ក.ប/គ.ក.រ និង គធ.ខប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ » ដើម្បីណែនាំដល់មន្ត្រីពាក់ព័ន្ធនឹងការងារនេះ ឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សៀវភៅណែនាំនេះ ជាសេចក្តីពន្យល់អំពីបច្ចេកទេសលើចំណុចសំខាន់ៗនៃកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការបញ្ជូនរាល់សម្ភារ ឯកសារបោះឆ្នោតតាមលំដាប់លំដោយនៃការងាររបស់ គ.ក.ប/គ.ក.រ និងតួនាទីភារកិច្ចរបស់ គធ.ខប ដែលត្រូវអនុវត្តផងដែរ។ គ.ក.ប/គ.ក.រ និង គធ.ខប ត្រូវសិក្សាស្វែងយល់តាមខ្លឹមសារនៃសៀវភៅណែនាំនេះ ដើម្បីអនុវត្តបច្ចេកទេសជាក់ស្តែងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងសម្រេចបានជោគជ័យ។

សៀវភៅណែនាំនេះ ក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

## I. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត និងវិធានការសន្តិសុខ

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប តាមចំនួនសមស្រប និងទាន់ពេលវេលាកំណត់។ គធ.ខប ត្រូវបញ្ជូន និងប្រគល់ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតជូន គ.ក.ប នីមួយៗ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត។

នៅពេលព្រឹកនៃថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត។

### ១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប

ប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប ដើម្បី ៖

- ឱ្យដឹងថា តើសមាជិក គ.ក.ប មានវត្តមានគ្រប់ទាំង ៦រូប ឬទេ ឬមានសមាជិកណាម្នាក់អវត្តមានមិនអាចមកបំពេញការងារបាននៅថ្ងៃបោះឆ្នោត។
- ចាត់តាំងសមាជិកឱ្យទទួលខុសត្រូវក្នុងការរៀបចំសម្ភារ ឯកសារបោះឆ្នោតតាមតួនាទីរៀងៗខ្លួន។
- ឱ្យសមាជិកម្នាក់ៗ រំឭកឡើងវិញ អំពីតួនាទី ភារកិច្ចដែលត្រូវបំពេញនៅថ្ងៃបោះឆ្នោតដូចមានចែងក្នុងសៀវភៅណែនាំ។

**ចំណាំ៖**

- ☛ ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចមកបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធានត្រូវតែជូនដំណឹងដល់ គធ.ខប ជាបន្ទាន់ដើម្បីដាក់អ្នកជំនួស។
- ☛ គធ.ខប ត្រូវជ្រើសរើសមនុស្ស ដែលមានលក្ខណសម្បត្តិសមស្របតាមច្បាប់កំណត់ឱ្យមកធ្វើការជំនួសតំណែងក្នុង គ.ក.ប ដែលអវត្តមាន៖
  - + ប្រសិនបើប្រធានមិនអាចមកបំពេញការងារបាន ដោយសារមូលហេតុណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយសមាជិកទី១ ចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យសុំបម្រើការងារ ត្រូវចូលកាន់តំណែងជំនួសសមាជិកទី១។
  - + ប្រសិនបើអនុប្រធានមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី១។
  - + ប្រសិនបើលេខាធិការមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី១។
- ☛ សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកដែលត្រូវបានជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញនូវ ប.ន.ព.ស និងសៀវភៅណែនាំ គ.ក.ប/គ.ក.រ និង គធ.ខប។

## ២. ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត

### ក. ពេលត្រួតពិនិត្យ

គ.ក.ប ត្រូវត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខនៅក្នុង ទ.១១០៧ ក្នុងនោះត្រូវ៖

- ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យ ទ.១១១២ ហើយសមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើ ទ.១១១២ និងរក្សាទុកឱ្យបានហ្មត់ចត់។
- ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ នៅក្នុង ទ.១១១២ ហើយផ្ញើ ទ.១១១២ នេះ ចំនួន ១ច្បាប់ ជាបន្ទាន់ទៅ គធ.ខប។ ប្រសិនបើសម្ភារដែលបាត់បង់ទៅនោះជាសម្ភារសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២រូប ទៅកាន់ លគធ.ខប ដើម្បីទទួលសម្ភារថ្មីជំនួសសម្ភារដែលខ្វះ ឬបានបាត់បង់ទៅ។
- គ.ក.ប ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យសម្ភារសំខាន់ៗ ដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត។ សម្ភារសំខាន់ៗទាំងនោះរួមមាន៖
  - សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់
  - ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត
  - បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ
  - ហិបឆ្នោត និងសោឃ្លុំមានលេខ
  - ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ។
- ចំពោះសម្ភារដទៃទៀត ប្រសិនបើមិនបានផ្តល់ដោយ គធ.ខប ទេនោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ដូចជា៖
  - កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត
  - ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុគំរូ
  - ប៊ិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង...។

**ចំណាំ៖**

ប្រធាន គ.ក.ប ត្រូវ ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ ឱ្យប្រាកដថា ពិតជាមានត្រានៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត។

ខ. ក្រោយពេលត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (នៅថ្ងៃសៅរ៍ ១ ថ្ងៃមុនថ្ងៃបោះឆ្នោត)

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១ច្បាប់ និងបញ្ជីបោះឆ្នោតផ្លូវការ ១ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត។*
- *បិទស្លាក និងលេខកូដការិយាល័យបោះឆ្នោត នៅលើច្រកទ្វារការិយាល័យបោះឆ្នោត។*
- *ចាត់ចែងសមាជិកឱ្យហាត់ដំឡើងហិបឆ្នោត និងបន្ទប់សម្ងាត់។*

គ. ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត

*ប្រធាន គ.ក.ប ត្រូវ*

- *រក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅផ្ទះប្រធាន ឬផ្ទះសមាជិកណាម្នាក់ ឬនៅទីណាមួយដែល គ.ក.ប ឯកភាពគ្នាថា មានសុវត្ថិភាព និងជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។*
- *ចាត់សមាជិក គ.ក.ប ៣នាក់ គិតទាំងប្រធាន ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព។*
- *ស្នើសុំកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត។*

## ៣. ការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត

ប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យ និងរៀបចំទីតាំងការិយាល័យបោះឆ្នោតឱ្យបានរួចរាល់ជាស្រេចនៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីត្រៀមសម្រាប់សមាជិកម្នាក់ៗនៃ គ.ក.ប រៀបចំសម្ភារ ឯកសារបោះឆ្នោត ទៅតាមកន្លែងរៀងៗខ្លួនឱ្យរួចស្រេចនៅម៉ោង ៦:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត។ ប្រធាន គ.ក.ប ត្រូវចាត់ចែង៖

- បោសសម្អាតការិយាល័យបោះឆ្នោត។
- រៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ដែលមានស្រាប់នៅក្នុងសៀវភៅណែនាំនេះ។
- រៀបចំតុ កៅអី និងសម្ភារដទៃទៀតឱ្យមានចំនួនគ្រប់គ្រាន់ សម្រាប់ដំណើរការបោះឆ្នោត ។
- រៀបចំបន្ទប់ឱ្យមានច្រកចេញ១ និងច្រកចូល១។
- បិទបង្អួចចាក់សោទ្វារ (បើមាន) និងស្នើសុំកម្លាំងសន្តិសុខយាមការពារ។
- ណាត់សមាជិកទាំងអស់ឱ្យមកកាន់ទីកន្លែងរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត ដើម្បីជួយដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។
- ជម្រាបសមាជិកទាំងអស់ ឱ្យត្រៀមអាហារសម្រាប់រយៈពេល ១ថ្ងៃ សម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប។

## គំរូប្លង់ការិយាល័យបោះឆ្នោត




## ៤. វិធានការសន្តិសុខ

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន អុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម៖

- ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច។
- ហាមនាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិណាម្នាក់ ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ លើកលែងតែក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធាន គ.ក.ប/គ.ក.រ ស្នើសុំឱ្យធ្វើអន្តរាគមន៍។
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។
- ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម៖
    - មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប
    - ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ឧប

- អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
- អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ
- ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប មានសំណូមពរ ក្នុងករណីចាំបាច់។

- ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។
- ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម៖
  - មន្ត្រីរាប់សន្លឹកឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប
  - ភ្នាក់ងារគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គជ.ខប
  - អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
  - ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរក្នុងករណីចាំបាច់។
- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖
  - ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
  - ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ
  - ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖
  - ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
  - ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

**ចំណាំ៖**

☛ ក្នុងករណីចាំបាច់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវហាមជនគ្រប់រូបចូលក្នុងបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។

- ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គ.ក.ប/គ.ក.រ។
- ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងដែលមានសុវត្ថិភាព។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ។

៥. ការប្រើប្រាស់បញ្ជីបោះឆ្នោត

| | |
|---|---|
| *បញ្ជីបោះឆ្នោតសម្រាប់ គធ.ខប ចំនួន ៣ច្បាប់* | *- ១ច្បាប់ បិទនៅ លគធ.ខប*<br>*- ១ច្បាប់ បិទនៅទីប្រជុំជនក្នុងរាជធានី ខេត្ត*<br>*- ១ច្បាប់ ទុកជាឯកសារ។* |
| *បញ្ជីបោះឆ្នោតសម្រាប់ គ.ក.ប ចំនួន ២ច្បាប់* | *- ១ច្បាប់ បិទនៅមុខទីតាំងការិយាល័យបោះឆ្នោត នៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត*<br>*- ១ច្បាប់ ទុកប្រើប្រាស់នៅថ្ងៃបោះឆ្នោត។* |

៦. សិទ្ធិបោះឆ្នោត និងលក្ខខណ្ឌបោះឆ្នោត

ក. អ្នកមានសិទ្ធិបោះឆ្នោត

តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងនៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ។

ខ. លក្ខខណ្ឌបោះឆ្នោត

| | |
|---|---|
| *បោះឆ្នោតបាន* | *- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ*<br>*- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួន ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត។* |
| *បោះឆ្នោតមិនបាន* | *- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬមិនមានលិខិតសម្គាល់ខ្លួន ឬមិនមានឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត*<br>*- មិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ទោះមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួន ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតក៏ដោយ។* |

## II. ការប្រព្រឹត្តទៅនៃការបោះឆ្នោត

សមាសភាព គ.ក.ប ទាំងអស់ ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដោយនាំយកសម្ភារ ឯកសារបោះឆ្នោតមកជាមួយផង។

ប្រធាន គ.ក.ប ត្រូវ៖

- ប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដោយត្រូវពិនិត្យបណ្ណសម្គាល់ ឬសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ និងប្រាប់ទីកន្លែង ដែលបានបម្រុងទុកជូន។
- ចាត់ចែងសមាជិក គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារិម សម្ភារ ឯកសារបោះឆ្នោត តាមតួនាទី ភារកិច្ច និងតាមទីកន្លែងរៀងៗខ្លួនតាមគំរូប្លង់ដែលបានរៀបចំទុក ១ថ្ងៃមុនថ្ងៃបោះឆ្នោត។
- ចាត់ចែង និងណែនាំសមាជិកទី២ ឱ្យបំពេញការងាររបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត។

**១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

**ក. ការរៀបចំសម្ភារ ឯកសារតាមគំរូប្លង់**

❖ តុ១ នៅខាងឆ្វេងដៃ បន្ទាប់ពីច្រកចូលបន្ទប់ សម្រាប់ប្រធាន។

| កន្លែងប្រធានមាន | - ទ.១២០២ (ពាក្យបណ្តឹង)<br>- ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារ ឯកសារមិនទាន់ប្រើប្រាស់ ត្រូវដាក់នៅក្បែរតុប្រធាន។ |
|---|---|

❖ តុវែង១ ឬខ្លី២ ដាក់ជាប់គ្នានៅខាងស្តាំដៃបន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា។

| កន្លែងលេខាធិការមាន | - បញ្ជីបោះឆ្នោត ១ច្បាប់<br>- កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ចំនួន ៣ច្បាប់<br>- ត្រាការិយាល័យបោះឆ្នោត និងទម្រង់បែបបទផ្សេងៗទៀត។ |
|---|---|

| កន្លែងអនុប្រធានមាន | - កញ្ចប់សន្លឹកឆ្នោត<br>- ស្រោមសំបុត្រដាក់ត្រាសម្ងាត់ និងតាំប៉ុងពណ៌ក្រហម។ |
|---|---|

❖ តុវែង១ ឬខ្លី២ សម្រាប់ដាក់ទ្របន្ទប់សម្ងាត់២ ដោយត្រូវមានចម្ងាយពីគ្នាយ៉ាងតិច ១ម៉ែត្រ និងឃ្លាតពីជញ្ជាំងប្រវែង ១ម៉ែត្រទៅ ១,៥០ម៉ែត្រដោយមិនអនុញ្ញាតឱ្យដាក់ក្បែរបង្អួចឡើយ។

| បន្ទប់សម្ងាត់នីមួយៗមាន | - ប៊ិក ១ដើម ចងខ្សែភ្ជាប់ស្រាប់<br>- ក្រដាសទ្រនាប់ ១សន្លឹក ពាសនៅលើតុ សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត។ |
|---|---|

❖ តុវែង១ សម្រាប់សមាជិកទី១ ដាក់នៅកណ្តាលបន្ទប់ទល់មុខតុប្រធាន។

| តុសមាជិកទី១ មាន | - ហិបឆ្នោតដំឡើងរួច<br>- ទឹកខ្មៅលុបមិនជ្រះចំនួន ២ដប<br>- ក្រណាត់សម្រាប់ជូតម្រាមដៃអ្នកបោះឆ្នោត។ |
|---|---|

❖ តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (បើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅក្រោយតុអនុប្រធាន និងលេខាធិការ។

ចំណាំ៖

☛ គ.ក.ប ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ស្ថិតនៅទីជិតខាងក្រោយអនុប្រធាន និងលេខាធិការ ល្មមដែលអាចមើលឃើញឯកសារបាន។

☛ ការផ្លាស់ប្តូរទីកន្លែងឈរ ឬអង្គុយរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវមានការអនុញ្ញាតពីប្រធាន គ.ក.ប។

**ខ. ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

ទន្ទឹមនឹងពេលរៀបចំសម្ភារ ឯកសារបោះឆ្នោត ប្រធាន គ.ក.ប ត្រូវណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ៖

- ត្រូវគោរព ច.ប.ព.ស ច.ប.ត.រ ប.ន.ព.ស ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប។
- ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។
- ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។
- មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ។
- មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត។
- មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ។
- ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ។
- ត្រូវបំពេញវត្តមានអ្នកសង្កេតការណ៍ ក្នុងអំឡុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីអង្គការ ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា។

## ២. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ នាទីដល់ម៉ោង ៦:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ប្រកាសដល់អ្នកបោះឆ្នោត និងអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ហាមប្រើប្រាស់ទូរស័ព្ទដៃ ម៉ាស៊ីន និងឧបករណ៍ថតរូប (លើកលែងតែអ្នកយកព័ត៌មាន ដែលបានទទួលស្គាល់ និងបានការអនុញ្ញាតពី គ.ជ.ប) ឬ/និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។*<br>*- ពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថា ត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ។*<br>*- បើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត។*<br>*- បង្ហាញហិបឆ្នោតទទេ ចំពោះអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកបិទគម្របក្នុងនៃហិបឆ្នោត រួចបិទភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ខ្ទាស់គន្លឹះគម្របក្នុង និងចាក់សោឃ្លុំមានលេខ។*<br>*- ចាត់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំនៅលើ ទ.១១០១។*<br>*- យកក្រដាសលេខកូដការិយាល័យបោះឆ្នោតចំនួន ២សន្លឹក និងបោះត្រាការិយាល័យ។*<br>*- បិទក្រដាសលេខកូដនោះភ្ជាប់ទៅនឹងជញ្ជាំងមុខក្រោយនៃហិបឆ្នោត*<br>*- អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោត។*<br>*- ចាត់លេខាធិការឱ្យកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោតនៅលើ ទ.១១០១។* |

**ចំណាំះ**

- មិនអនុញ្ញាតឱ្យយកហិបឆ្នោតចេញពីការិយាល័យបោះឆ្នោត។
- មិនអនុញ្ញាតឱ្យបើកហិបឆ្នោតដាច់ខាត។
- សមាជិកទី២ នៅខាងក្រៅការិយាល័យបោះឆ្នោតអាចប្រើប្រាស់ទូរស័ព្ទបាន ដើម្បីទំនាក់ទំនងការងារ។

**ប្រធាន គ.ក.ប បង្ហាញហិបឆ្នោតទទេដល់សមាជិក គ.ក.ប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**



### ៣. នាវកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០ នាទីដល់ម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត

ប្រធាន គ.ក.ប ត្រូវចាត់ចែងត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត លេខរៀងសន្លឹកឆ្នោត រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្ដែង និងពិនិត្យត្រាសម្ងាត់ផ្លូវការនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត។

#### ក. ការត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត

| ប្រធាន គ.ក.ប ត្រូវ | - *ចាត់អនុប្រធានឱ្យ៖*<br>▪ *ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យដឹងប្រាកដថា មិនត្រូវបានគេរុះរើឡើយ។*<br>▪ *បើកកញ្ចប់សន្លឹកឆ្នោតពិនិត្យមើល ដើម្បីឱ្យដឹងប្រាកដថា សន្លឹកឆ្នោតនេះជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់ការិយាល័យបោះឆ្នោតនោះប្រាកដមែន (បើមិនមែន ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់ តាមរយៈ គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ)។*<br>▪ *រាប់សន្លឹកឆ្នោតដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះ ពី៥០ ដល់៩៩ សន្លឹក។*<br>- *ចាត់លេខាធិការឱ្យ៖*<br>▪ *កត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្ដែង (ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្ដែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោត ដែលត្រូវប្រគល់ឱ្យក្ដី) និងកត់ត្រាលេខរៀងដើមដំបូងបង្អស់ និងលេខរៀងចុងបញ្ចប់នៅលើគល់សន្លឹកឆ្នោតទៅក្នុង ទ.១១០១។*<br>▪ *ពិនិត្យចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុង ទ.១១០១។* |
|---|---|

#### ខ. ការត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់

| ប្រធាន គ.ក.ប ត្រូវ | - *ពិនិត្យ និងបង្ហាញអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ដើម្បីឱ្យដឹងប្រាកដថា ស្រោមសំបុត្រដាក់ត្រាសម្ងាត់មិនត្រូវបានគេរុះរើឡើយ។*<br>- *បើកស្រោមសំបុត្រដែលមានត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។*<br>- *ដកយកត្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស។*<br>- *លើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបានរូបសញ្ញានៃត្រានោះ។*<br>- *បោះត្រាសម្ងាត់នៅលើជ្រុងខាងស្ដាំប៉ែកខាងលើនៃ ទ.១១០១។* |
|---|---|

#### ចំណាំ

☛ ករណីសម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតត្រូវបានទទួលនៅក្រោយម៉ោង ៦:៣០ នាទីព្រឹក ប៉ុន្តែមិនហួសពីម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោតទេ។ ករណីនេះ ប្រធាន គ.ក.ប ត្រូវ ៖

- ព្យួរការអនុវត្តនីតិវិធីបន្ទាប់នៃការបោះឆ្នោតនៃការិយាល័យនោះ ជាបណ្ដោះអាសន្នសិន រហូតទាល់តែការពិនិត្យ និងបង្ហាញហិបឆ្នោតព្រមទាំងការពិនិត្យសន្លឹកឆ្នោត និងត្រាសម្ងាត់ត្រូវបានបំពេញចប់សព្វគ្រប់។
- ចាត់លេខាធិការកត់ត្រាពេលម៉ោងនៃការពិនិត្យ និងបង្ហាញហិបឆ្នោត និងកត់ត្រាចំនួនសន្លឹកឆ្នោតទទួលជាក់ស្ដែង ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតទៅក្នុង ទ.១១០១ ឱ្យបានច្បាស់លាស់។
- បើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០ នាទីព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ នាទីព្រឹកឡើយ។

**៨. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត គឺ៖**

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ទាំង ៣ប្រភេទ ឬ
- លិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬ
- លិខិតសម្គាល់ខ្លួនជាក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ឬ
- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)។

**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ទាំង ៣ប្រភេទ**




ឬ




ឬ




**៩. ការបោះឆ្នោតចាប់ពីម៉ោង ៧:០០ នាទីព្រឹកដល់ម៉ោង ៣:០០ នាទីរសៀល**

ប្រធាន គ.ក.ប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០ នាទីព្រឹក នៃថ្ងៃបោះឆ្នោត។

ប្រធាន គ.ក.ប ត្រូវចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ យ៉ាងយូរ ១ម៉ោងម្ដង ប្រធានត្រូវត្រួតពិនិត្យក្នុងបន្ទប់សម្ងាត់អំពីសុវត្ថិភាព និងសណ្ដាប់ធ្នាប់ សម្ភារ ដែលបំពាក់នៅទីនោះ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។ ប្រធាន គ.ក.ប ត្រូវចាត់ចែងការងារតាមលំដាប់លំដោយដូចតទៅ៖

**សមាជិកទី៣ ត្រូវ**

- ជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តកន្ទុយគ្នានៅក្នុងបរិវេណខាងក្នុងអំពីអ្នកបោះឆ្នោតដែលត្រូវផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត។
- ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេ ដល់អ្នកបោះឆ្នោតជាជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនដែលមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនដែលមានពិការភាពនោះ បន្ទាប់មកគឺអ្នកឈរមុខគេក្នុងជួរ។
- រំឭកអ្នកបោះឆ្នោតឱ្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅមុខទីតាំងការិយាល័យបោះឆ្នោត៖
  - បើរកឃើញឈ្មោះ ត្រូវឱ្យគាត់ចាំលេខរៀង ដើម្បីជម្រាបជូនលេខាធិការ។
  - បើរកមិនឃើញឈ្មោះ ត្រូវជម្រាបជូនសមាជិកទី២ ដើម្បីជួយរកឈ្មោះ។
- ឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ ។
- ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត។
- ជម្រាបអ្នកបោះឆ្នោតឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន។
- អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលម្តង ១នាក់ និងមានវត្តមានក្នុងការិយាល័យបោះឆ្នោតចំនួន ៤នាក់ ក្នុងពេលតែមួយ។
- ហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយនៅពេលការបោះឆ្នោតឈានចូលដល់ម៉ោង ៣:០០នាទីរសៀល។

**សមាជិកទី២ ត្រូវ**

- ចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង។
- ជួយរកឈ្មោះ និងលេខរៀងអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត។
- ប្រសិនបើក្នុងបណ្ណព័ត៌មានអ្នកបោះឆ្នោតឃើញឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតផ្សេងជម្រាបគាត់ឱ្យទៅកាន់ការិយាល័យបោះឆ្នោតនោះដើម្បីបោះឆ្នោត។
- អាចផ្តល់បណ្ណលេខរៀងតាមលំដាប់មុនក្រោយ (ក្នុងករណីចាំបាច់)។
- ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាជាជួរ។
- ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ៣:០០នាទីរសៀលនៃថ្ងៃបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតទៀត អ្នកទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត។ ក្នុងករណីនេះ សមាជិកទី២ ត្រូវប្រកាសអញ្ជើញអ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតឱ្យចូលក្នុងជួរ និងត្រូវប្រមូលយក អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ឱ្យសមាជិកទី៣ នៅត្រង់មាត់ទ្វារ។

# សកម្មភាពនៅក្នុងការិយាល័យបោះឆ្នោត




| | |
|---|---|
| *លេខាធិការត្រូវ* | *- ត្រួតពិនិត្យម្រាមដៃអ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះ។*<br>*- ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មានអ្នកបោះឆ្នោត (បើមាន) រួចប្រគល់បណ្ណនេះជូនគាត់វិញ។*<br>*- ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត។*<br>*- ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិកបញ្ជាក់ការបានមកបោះឆ្នោតរបស់គាត់ ក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ និងឱ្យអ្នកបោះឆ្នោតផ្ដិតនៅលើបញ្ជីបោះឆ្នោត ត្រង់ចន្លោះទំនេរនៃឈ្មោះអ្នកបោះឆ្នោត។*<br>*- ហុច អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ របស់គាត់បន្តទៅឱ្យអនុប្រធាន បើឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនរបស់អ្នកបោះឆ្នោតដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។*<br>*- ជម្រាបគាត់ឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន។* |

**ចំណាំ៖**

- ប្រសិនបើពិនិត្យឃើញថា ម្រាមដៃគាត់ប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ឬរូបថត ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនគាត់ទៅជួបប្រធាន និងរាយការណ៍ពីករណីនេះ។
- ប្រសិនបើរកមិនឃើញមានឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ត្រូវជូនគាត់ទៅជួបប្រធាន និងរាយការណ៍។

| | |
|---|---|
| *អនុប្រធានត្រូវ* | - *ហែកសន្លឹកឆ្នោត ១សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត។*<br>- *បោះត្រាសម្ងាត់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោតរួចបត់សន្លឹកឆ្នោតជា ៤ផ្នត់។*<br>- *ជូនសន្លឹកឆ្នោតនោះ និងអ.ខ ឬលិខិតសម្គាល់ខ្លួន ឬឯ.អ ទៅអ្នកបោះឆ្នោត។*<br>- *ណែនាំអ្នកបោះឆ្នោតថា៖*<br>▪ *នេះគឺជាសន្លឹកឆ្នោត។*<br>▪ *អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) គូសសញ្ញាគាំទ្រ នៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែ ១គត់ ដែលអ្នកពេញចិត្ត។*<br>▪ *ពិចារណាឱ្យហ្មត់ចត់មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្តូរចិត្ត។*<br>▪ *មុននឹងចេញពីបន្ទប់សម្ងាត់អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលអ្នកបានគូសបត់ចូលក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ។*<br>▪ *ដើរទៅកាន់តុដាក់ហិបឆ្នោត លើកសន្លឹកឆ្នោតដែលបត់រួចហើយ និងមានត្រាសម្ងាត់នៅខាងខ្នងបង្ហាញសមាជិកទី១ ដែលនៅក្បែរនោះ រួចស៊កសន្លឹកឆ្នោតតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។*<br>- *ផ្តល់សន្លឹកឆ្នោត ១សន្លឹកថ្មីទៀត ចំពោះអ្នកបោះឆ្នោតដែលបានធ្វើឱ្យខូច ឬរហែកដោយអចេតនា ឬត្រូវផ្លាស់ប្តូរចិត្ត តាមការអនុញ្ញាតពីប្រធាន។* |

**ចំណាំ៖**

- អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោត និងអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់។
- ការបោះត្រាសម្ងាត់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោតនីមួយៗ មិនត្រូវយកសៀវភៅសន្លឹកឆ្នោតធ្វើជាទ្រនាប់ និងបត់សន្លឹកឆ្នោតឡើយ ដើម្បីបង្ការការប្រឡាក់ទឹកត្រាលើសន្លឹកឆ្នោតផ្សេងទៀត។

| | |
|---|---|
| *សមាជិកទី១ ត្រូវ* | - *ឱ្យអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបានបត់រួចនោះ ដោយដាក់បែរផ្នែកខាងខ្នងដែលមានបោះត្រាសម្ងាត់ទៅរកគាត់ ហើយស៊កវាដោយខ្លួនឯងតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។*<br>- *ពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែ ១សន្លឹក ដែលមានត្រាសម្ងាត់ជាផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនោះ។*<br>- *ជូត និងជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត (ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ) របស់អ្នកបោះឆ្នោតដែលបានបោះឆ្នោតរួច ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ និងឱ្យគាត់រង់ចាំបន្តិច ដើម្បីឱ្យទឹកខ្មៅស្ងួតមុននឹងចេញពីការិយាល័យបោះឆ្នោត។*<br>- *បិទគម្របដបទឹកខ្មៅឱ្យជិត ដើម្បីការពារកុំឱ្យវាហួត បើគ្មានអ្នកបោះឆ្នោតក្នុងរយៈពេលយូរ និងក្រឡុកវារាល់ ៣០នាទីម្តង។*<br>- *បម្រុងទុកទឹកខ្មៅលុបមិនជ្រះ ១ដបទៀត សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទី១។* |

**ចំណាំ៖**

សមាជិកទី១ ត្រូវ៖

- ច្នៃប្រឌិតរកកំប៉ុង ឬដបជ័រ ដោយកាត់ឱ្យខ្លី ដាក់ដីខ្សាច់ សម្រាប់ដាក់ទប់ដបទឹកខ្មៅលុបមិនជ្រះ។

- រាយការណ៍ជាបន្ទាន់ជូនប្រធាន គ.ក.ប ប្រសិនបើចាប់ភស្តុតាងបានថា មានអ្នកបោះឆ្នោតណាម្នាក់មានបំណងសឹកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត។
- បិទភ្ជិតសន្ទះប្រឡោះសឹកសន្លឹកឆ្នោតជាបណ្តោះអាសន្ន ប្រសិនបើគ្មានអ្នកបោះឆ្នោតមកបោះឆ្នោត និងត្រូវបើកសន្ទះវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត។

## ៦. ការងាររបស់ប្រធានក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត

### ក. ករណីអ្នកបោះឆ្នោតមានម្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ឬបថត ឬទិន្នន័យមិនដូចគ្នា

*ប្រធាន គ.ក.ប ត្រូវ*

- *អញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកកត់សម្គាល់បញ្ហានេះ។*
- *ឱ្យអ្នកបោះឆ្នោតនោះពន្យល់បំភ្លឺអំពីបញ្ហានោះ។ ប្រសិនបើការបំភ្លឺនោះមិនសមហេតុផល សន្និដ្ឋានថា គាត់មានបំណងបោះឆ្នោតលើសពី ១ដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោត ដែលត្រូវទទួលទោសតាមច្បាប់។*
- *ដកហូត អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ ជាបណ្តោះអាសន្ន រួចបញ្ជូនទៅ គឃ.ខប ដើម្បីចាត់វិធានការបន្តទៀត។*
- *ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នេះ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងស្រង់ឈ្មោះ និងទិន្នន័យពីក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ សម្រាប់ការតាមដានបន្ថែមទៀត។*
- *ប្រសិនបើគាត់មិនយល់ព្រមតាមវិធានការខាងលើ ប្រធាន គ.ក.ប ឬ គឃ.ខប ស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។*

### ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ

*ប្រធាន គ.ក.ប ត្រូវ*

- *ជម្រាបគាត់ថា គាត់ពុំអាចបោះឆ្នោតនៅការិយាល័យនេះបានទេ ព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនេះ។*
- *សួររកបណ្ណព័ត៌មានរបស់គាត់ ដើម្បីជម្រាបគាត់អំពីទីតាំងការិយាល័យបោះឆ្នោត។*
- *ជម្រាបគាត់ឱ្យចេញពីការិយាល័យបោះឆ្នោត។*

### គ. ករណីអ្នកបោះឆ្នោតណាម្នាក់មានបំណងសឹកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត

- ចំពោះអ្នកបោះឆ្នោតមិនមែនជាបេក្ខជនឈររឈ្មោះ ប្រធាន គ.ក.ប ត្រូវ ៖
  - ប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោតមុននឹងមានវិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ។
  - ឃាត់អ្នកបោះឆ្នោតនោះមិនឱ្យបោះឆ្នោត
  - ដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (បើមាន) ដាក់ក្នុងស្រោមសំបុត្រមានកាខ្វងស្រាប់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត»

- ដកហូត អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ ជាបណ្ដោះអាសន្ន
- ចាត់ចែងធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ទៅ គធ.ឃប។

❖ **ចំពោះអ្នកបោះឆ្នោតជាបេក្ខជនឈរឈ្មោះបោះឆ្នោត**

គធ.ឃប ត្រូវប្ដឹងទៅ គ.ជ.ប ទៀត ដើម្បីចាត់វិធានការតាមច្បាប់ ប្រសិនបើមានភស្ដុតាងគ្រប់គ្រាន់។

**ឃ. ករណីអ្នកបោះឆ្នោតជាជនដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន**

អ្នកបោះឆ្នោតជាជនដែលមានពិការភាព ដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន អាចជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬអាចស្នើសុំជំនួយពីប្រធាន គ.ក.ប។ ប្រធាន គ.ក.ប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាពនោះ ឬអាចចាត់សមាជិក គ.ក.ប ណាម្នាក់ជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន។

- អ្នកជំនួយជនពិការ ត្រូវសួរអ្នកបោះឆ្នោតជាជនដែលមានពិការភាពថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយមួយណា?
- អ្នកជំនួយត្រូវសួរតិចៗធ្វើយ៉ាងណាកុំឱ្យអ្នកដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ។
- អ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោត តាមការជ្រើសរើសរបស់អ្នកបោះឆ្នោតដែលមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម រួចត្រូវនាំអ្នកបោះឆ្នោតទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់ទៅក្នុងហិបឆ្នោត។
- អ្នកជំនួយជនដែលមានពិការភាព ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

**ង. ករណីអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង**

ចំពោះអ្នកបោះឆ្នោតដែលពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះឱ្យប្រើក្របក្រដាសពិសេស ដែលជាសម្ភារជំនួយដល់ការបោះឆ្នោត។ អនុប្រធាន គ.ក.ប ត្រូវប្រគល់ក្របក្រដាសពិសេស ដែលមានដាក់សន្លឹកឆ្នោតខាងក្នុងជូនទៅអ្នកបោះឆ្នោតដែលជាជនពិការ និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូចដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា៖

- អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូចដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលមានបញ្ជីបេក្ខជនឈរឈ្មោះក្នុងភូមិភាគនេះ។ ឯប្រហោងរាងមូលតូច គឺជាកំណត់សម្គាល់គណបក្សនយោបាយដែលពុំបានឈរឈ្មោះក្នុងមណ្ឌលភូមិភាគនេះ។
- អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយ ដែលខ្លួនពេញចិត្ត។

- អ្នកត្រូវប្រើប៊ិកគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្ដាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្សដែលអ្នកពេញចិត្ត។
- អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

**ច. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្សនយោបាយ**

*ប្រធាន គ.ក.ប ត្រូវ*

- *ព្រមានផ្ទាល់មាត់ ចំពោះការប៉ុនប៉ងលើកទី១។*
- *ចាត់ទុកជាការរំលោភលើភាពសម្ងាត់នៃការបោះឆ្នោត ត្រូវបណ្ដេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ព.ស ចំពោះការប៉ុនប៉ងលើកទី២។*
- *ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នេះក្នុងកំណត់ហេតុមួយដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។*
- *បញ្ជូនកំណត់ហេតុជូន គធ.ឃប ក្នុងករណីជនប្រព្រឹត្តល្មើសគោលការណ៍សម្ងាត់នៃការបោះឆ្នោតនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត។*

- បន្ទាប់ពីបានទទួលកំណត់ហេតុខាងលើ គធ.ឃប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។
- ប្រសិនបើមានភស្តុតាងបញ្ជាក់ថា បានរំលោភពិតប្រាកដមែន គធ.ឃប ត្រូវបញ្ជូនករណីនេះទៅ គ.ជ.ប ដើម្បីចាត់វិធានការតាមច្បាប់។

**ឆ. ករណីសន្លឹកឆ្នោតខូច ឬរហែកដោយអចេតនា ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយតែបានផ្លាស់ប្ដូរចិត្តវិញ**

*ប្រធាន គ.ក.ប ត្រូវ*

- *អនុញ្ញាតឱ្យអនុប្រធានផ្ដល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោត ១សន្លឹកទៀត ហើយឱ្យតែ ១លើកនេះគត់។*
- *ប្រាប់គាត់ឱ្យបត់សន្លឹកឆ្នោតខូច ឬរហែក ឬផ្លាស់ប្ដូរចិត្តតាមផ្នត់ដើម រួចដាក់ទៅក្នុងស្រោមសំបុត្រដែលមានកាខ្វងស្រាប់ «សន្លឹកឆ្នោតខូច»។*
- *សម្រេចមិនព្រមផ្ដល់សន្លឹកឆ្នោត ១សន្លឹកផ្សេងទៀតតាមការស្នើសុំបានឡើយ ប្រសិនបើអ្នកបោះឆ្នោតមកសុំបន្តបន្ទាប់គ្នាដែលចាត់ទុកថាជាភាពមិនប្រក្រតី ហើយឱ្យលេខាធិការកត់ត្រាករណីទាំងនោះចូលក្នុង ទ.១១០១។*
- *រំឭកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោតអំពីរបៀបបង្ការសន្លឹកឆ្នោតខូច*
- *ធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។*

**ជ. ករណីមានការជំទាស់ ឬតវ៉ាពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ*

- *ឱ្យភ្នាក់ងារគណបក្សនយោបាយលើកការជំទាស់ ឬតវ៉ានោះមកខ្លួនផ្ទាល់។*
- *ឱ្យបង្ហាញពីមូលហេតុ ឬភស្តុតាងដែលនាំឱ្យគាត់ជឿថាមានភាពមិនប្រក្រតី ឬមានការរំលោភលើ ច.ប.ព.ស ឬ ប.ន.ព.ស។*

❖ ប្រសិនបើជំទាស់សមហេតុផល

*ប្រធាន គ.ក.ប ត្រូវ*

- *បញ្ឈប់ជាបណ្តោះអាសន្ន កិច្ចប្រតិបត្តិការបោះឆ្នោត។*
- *ស្តាប់ការជំទាស់ ឬតវ៉ានោះ។*
- *ពិភាក្សាជាមួយសមាជិក គ.ក.ប ដទៃទៀត។*
- *សម្រេចយល់ព្រម ឬបដិសេធការជំទាស់ ឬតវ៉ានោះ។*

❖ ប្រសិនបើយល់ព្រមតាមការជំទាស់ ឬការតវ៉ានោះ ប្រធានត្រូវណែនាំ និងរំឭកសមាជិក គ.ក.ប និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតអំពីខ្លឹមសារពាក់ព័ន្ធ និងត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។

❖ ប្រសិនបើបដិសេធការជំទាស់ ឬតវ៉ា៖

- ផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះជូនភ្នាក់ងារគណបក្សនយោបាយ
- ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាករណីជំទាស់ ឬតវ៉ានេះទៅក្នុង ទ.១១០១ ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាជាមួយ។ ប្រសិនបើគាត់មិនយល់ព្រមចុះហត្ថលេខា ករណីនៃការជំទាស់ ឬតវ៉ានោះមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុទេ។
- ការសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត។
- ផ្តល់ ទ.១២០២ ជូនគាត់សម្រាប់ប្តឹងទៅ គធ.ឃប (ប្រសិនបើមានការស្នើសុំ)។

**ឈ. ករណីមានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត (ទោះបីនៅក្នុងការិយាល័យបោះឆ្នោតក្តី ឬកំពុងឈរជាជួរនៅក្នុងបរិវេណខាងក្នុងក្តី)**

*ប្រធាន គ.ក.ប ត្រូវ*

- *បញ្ជាអ្នកបោះឆ្នោតនោះឱ្យចេញទៅក្រៅការិយាល័យបោះឆ្នោត និងចេញឱ្យផុតពីបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត។*
- *ប្រសិនបើគាត់មិនព្រមចេញ ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។*

**ញ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបានតទៅទៀត**

ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខ ឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយនៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត។

សកម្មភាពរំខានដល់កម្រិតមិនអាចបោះឆ្នោតបានមាន៖

- ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញពាក្យសម្តីគំរាមកំហែង ឬជេរប្រមាថមាក់ងាយ
- ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- ការរុញច្រានដោយប្រើកម្លាំងធ្ងន់
- ការគប់វត្ថុផ្សេងៗ សំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត
- ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត
- ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ

- ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់។

ង. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ៣:០០ នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត

| ប្រធាន គ.ក.ប ត្រូវ | *- ចាត់សមាជិកទី២ ឱ្យដើរប្រមូល អ.ខ ឬលិខិតសម្គាល់ខ្លួន ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្ដើមប្រមូលពីអ្នកឈរក្រោយគេបង្អស់រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ជូនសមាជិកទី៣។*<br>*- ចាត់សមាជិកទី៣ ឱ្យហៅឈ្មោះម្នាក់ម្ដងៗរហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោត។* |
|---|---|

ចំណាំ៖

- អ្នកបោះឆ្នោតណាដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោង ៣:០០ នាទីរសៀលនៃថ្ងៃបោះឆ្នោតទេ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។
- ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្ដី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ៣:០០ នាទីរសៀលនៃថ្ងៃបោះឆ្នោតបានឡើយ។
- ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានមកបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ៣:០០ នាទីរសៀលបាន។

## III. ការបិទការបោះឆ្នោត

នៅពេលអ្នកមានសិទ្ធិបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី៣ ឱ្យចាត់វិធានការចាំបាច់ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោត កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល។ បន្ទាប់មកប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ និងអនុវត្តការងារជាបន្តបន្ទាប់ដូចតទៅ៖

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | - បិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២នៃហិបឆ្នោត។<br>- បិទក្រដាសស្ដើង ១សន្លឹកដែលមានចុះហត្ថលេខារបស់គាត់ និងភ្នាក់ងារគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២ នោះ។ |

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | - បិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំង២ នៃហិបឆ្នោត និងអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំង២ នោះ។<br>- ចាត់លេខាធិការឱ្យកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) អំពីពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំង២។<br>- ចាត់វិធានការការពារហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់។ |

**១. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច**

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | - ចាត់លេខាធិការឱ្យរាប់ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដោយរាប់ចំនួនគំនូសសញ្ញាដែលបានគូសសម្គាល់ក្នុងបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត។<br>- ឱ្យអនុប្រធានកំណត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតមិនទាន់បានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងរាប់ចំនួនសន្លឹកឆ្នោតខូចដោយឡែកពីគ្នា។<br>- ឱ្យលេខាធិការ និងអនុប្រធានធ្វើការផ្ទៀងផ្ទាត់គ្នា ប្រសិនបើឃើញថា ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែងដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើមានចំនួនស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនោះ ត្រូវចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនស្មើគ្នានោះនៅក្នុង ទ.១១០១។<br>- ប្រសិនបើឃើញថា មានភាពខុសគ្នា៖<br>▪ ចាត់លេខាធិការឱ្យរាប់ចំនួនគំនូសសញ្ញាសម្គាល់អ្នកបោះឆ្នោតដែលបានមកបោះឆ្នោត ជាលើកទី២។<br>▪ ឱ្យអនុប្រធានផ្ទៀងផ្ទាត់ និងរាប់ឡើងវិញដៃរនូវចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូចដែលសរុបមក ត្រូវស្មើនឹងចំនួនសន្លឹកឆ្នោតទទួលជាក់ស្ដែង។ |

**ប្រធាន គ.ក.ប ត្រូវ**

- ប្រសិនបើឃើញថា នៅតែមានភាពខុសគ្នាទៀត៖
  - ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនដែលខុសគ្នានោះ នៅក្នុង ទ.១១០១។
  - ភាពខុសគ្នានោះ មិនត្រូវបានកំណត់ជាភាពមិនប្រក្រតីមួយនោះទេ
- ចាត់សមាជិកទី២ ឱ្យកាត់ ឬចោះសន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ដោយកន្ត្រៃ ឬប្រដាប់ចោះ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ។
  - ឱ្យអនុប្រធានដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែ១ រួចបិទឱ្យជិត។

## ២. រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត

ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត = ចំនួនសន្លឹកឆ្នោតដែលបានទទួលដាក់ស្តែង − ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច

## ៣. កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់

**ប្រធាន គ.ក.ប ត្រូវ**

- ចាត់លេខាធិការឱ្យ៖
  - កត់ត្រាបន្ថែមនូវលេខសោឃ្លុំដែលនឹងត្រូវប្រើប្រាស់សម្រាប់ចាក់ឃ្លុំមាត់ស្បោង «ខ» នៅក្នុង ទ.១១០១
  - បោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃ ទ.១១០១។
  - ចុះហត្ថលេខាលើ ទ.១១០១ ទាំង ២ច្បាប់
- ពិនិត្យ និងចុះហត្ថលេខាលើ ទ.១១០១ ទាំង ២ច្បាប់ រួចឱ្យលេខាធិការបោះត្រាការិយាល័យបោះឆ្នោត
- ដាក់បង្ហាញកំណត់ហេតុនេះចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ
- អញ្ជើញភ្នាក់ងារគណបក្សនយោបាយ ឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។

ទ.១១០១ ចំនួន ២ច្បាប់
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្នងថា «កំណត់ហេតុនៃការបោះឆ្នោត ផ្ញើជូន គ.ជ.ប»
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្នងថា «កំណត់ហេតុនៃការបោះឆ្នោត ផ្ញើជូន គធ.ខប»

## ៤. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» (មិនទាន់បិទផ្និតការសុវត្ថិភាព)

ប្រធាន គ.ក.ប ត្រូវរៀបចំវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» ដែលមាន៖

- ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» (បើមាន)
- ស្បោងប្លាស្ទិកដាក់«សន្លឹកឆ្នោតមិនបានប្រើនិងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត» (បើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (បើមាន)។

**ចំណាំ៖** ប្រធាន គ.ក.ប ត្រូវ ៖

- ចាត់ចែងត្រួតពិនិត្យឱ្យបានហ្មត់ចត់ថា សម្ភារ ឯកសារខាងលើត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» គ្រប់សព្វហើយ។
- កុំទាន់បិទការសុវត្ថិភាពកញ្ចប់សុវត្ថិភាព «ក» ព្រោះត្រូវរង់ចាំដាក់ ទ.១១០២ ទ.១១០៨ និងស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន) ចូលក្នុងកញ្ចប់សុវត្ថិភាព «ក» បន្ថែមទៀត។
- សរសេរលេខកូដការិយាល័យបោះឆ្នោតលើកញ្ចប់សុវត្ថិភាព «ក» ផ្នែកខាងក្រៅដោយប៊ិកហ្វឺតលុបមិនជ្រះ។
- ចាត់ចែងរក្សាទុកកញ្ចប់សុវត្ថិភាព «ក» យ៉ាងហ្មត់ចត់ និងមានសុវត្ថិភាពក្នុងពេលកំពុងដំណើរការរាប់សន្លឹកឆ្នោត។

(មិនទាន់បិទការសុវត្ថិភាព)

**កញ្ចប់សុវត្ថិភាព «ក»**

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |

**ឃុំ/សង្កាត់ រាជធានី ខេត្ត ការិយាល័យបោះឆ្នោត**

- *ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប*
- *ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត*
- *ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច»(បើមាន)*
- *ស្បោងប្លាស្ទិកដាក់«សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»*
- *ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់*
- *ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត(បើមាន)*
- *ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត(បើមាន)។*

## ៤. ការរៀបចំទុកដាក់សម្ភារ ឯកសារនៅសល់

ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកឱ្យ៖

- រៀបចំទុកដាក់សម្ភារ ឯកសារដែលនៅសល់ក្នុងកេសស័ង្កសី។
- វេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក។
- រុះរើបន្ទប់សម្ងាត់ទាំង២ រួចច្រកទៅក្នុងការុងនីឡុងដែលបានប្រើពេលទទួល។

- រៀបចំទុកដាក់សម្ភារឯកសារខាងលើនោះឱ្យមានសុវត្ថិភាពនៅក្នុងការិយាល័យបោះឆ្នោត។

## IV. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតាមការិយាល័យបោះឆ្នោតនីមួយៗ ដែលមានទីតាំងនៅទីប្រជុំជនរាជធានី ខេត្ត លើកលែងតែការិយាល័យបោះឆ្នោតណាដែលមានសេចក្តីសម្រេចផ្សេងពីនេះ ដោយ គ.ជ.ប។ គ.ក.ប ក្លាយជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត។

ការរាប់សន្លឹកឆ្នោតត្រូវធ្វើបន្ទាប់ពីការបិទការបោះឆ្នោត និងការធ្វើកំណត់ហេតុនៃការបោះឆ្នោតចប់រួចរាល់នាល្ងាចថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។

ការផ្ទៀងផ្ទាត់ និងការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែ ១កន្លែងសម្រាប់ការិយាល័យបោះឆ្នោត១ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ហើយត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនត្រូវឈប់សម្រាកឡើយ។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន ទ.១១១៥។ នៅចំពោះមុខមុនពេល ចាប់ផ្តើមរាប់សន្លឹកឆ្នោត ហើយអាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន(បើមាន)ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យចប់ចុងចប់ដើម។ ប្រធាន គ.ក.រ ត្រូវចាត់ចែងរៀបចំតាមគំរូប្លង់សម្រាប់ការរាប់សន្លឹកឆ្នោត និងមានវិធានការការពារសន្តិសុខក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

### ១. ការចាត់ចែងរៀបចំបន្ទប់រាប់សន្លឹកឆ្នោត

*ប្រធាន គ.ក.ប ត្រូវ*

- *ត្រៀមភ្លើងសម្រាប់បំភ្លឺក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់។*
- *អង្គុយចុងតុម្ខាងទល់មុខលេខាធិការ។ អនុប្រធាន និងសមាជិកទី១ អង្គុយអមសងខាងទល់មុខគ្នា។*
- *ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញ ចូល មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោតដែលមិនត្រូវបានប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត។*
- *ចាត់ចែងរៀបចំតាមប្លង់ការិយាល័យរាប់សន្លឹកឆ្នោត និងទុកដាក់សម្ភារ ឯកសារដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព។*
- *រៀបតុធំ១ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីចំនួន៤ សម្រាប់សមាជិក គ.ក.រ ដាក់ចំកណ្តាលបន្ទប់ដែលអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើរចុះឡើងជុំវិញតុ ដើម្បីសង្កេតមើលសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត។*
- *បិទផ្ទាំងក្រដាសធំ ១សន្លឹកភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀនសម្រាប់កត់ត្រាសំឡេងឆ្នោត។*
- *លើកហិបឆ្នោតដាក់ចំកណ្តាលតុ និងដាក់កញ្ចប់សុវត្ថិភាព « ក » រាល់សម្ភារ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនៅលើតុត្រង់កន្លែងខ្លួនអង្គុយ។*

**២. វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី ដើម្បីចង់ដឹងថា អ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត**

*ប្រធាន គ.ក.រ ត្រូវ*

- *ព្រមានផ្ទាល់មាត់ចំពោះការធ្វើសកម្មភាពលើកទី១។*
- *បណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ព.ស ចំពោះការធ្វើសកម្មភាពលើកទី២។*
- *ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នោះក្នុងកំណត់ហេតុមួយដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។*
- *បញ្ជូនកំណត់ហេតុនេះជូន គធ.ខប ជាបន្ទាន់។*

- នៅពេលទទួលបានកំណត់ហេតុនេះ គធ.ខប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។
- ប្រសិនបើមានភស្តុតាងបញ្ជាក់ថា បានរំលោភពិតប្រាកដមែន គធ.ខប ត្រូវបញ្ជូនករណីនេះទៅ គ.ជ.ប ដើម្បី គ.ជ.ប ចាត់វិធានការតាមផ្លូវច្បាប់។

**៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ**

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេស ប្រធាន គ.ក.ប អនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

**ក. សន្លឹកឆ្នោតបានការ**

- សន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង
- សន្លឹកឆ្នោតមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងស្របនឹងគណបក្សនយោបាយណាមួយ។

**ខ. សន្លឹកឆ្នោតមិនបានការ**

សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈដែលក្នុងនោះរួមមាន ៥ប្រភេទ ។

**ខ.១ សន្លឹកឆ្នោតមិនផ្លូវការ៖**

- សន្លឹកឆ្នោតមានខ្នាតតូច ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅតាមមណ្ឌលភូមិភាគពាក់ព័ន្ធ សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅតាមមណ្ឌលភូមិភាគនីមួយៗ

- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់មណ្ឌលភូមិភាគនីមួយៗ
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ។

**ខ.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែលពុំអាចសន្និដ្ឋានថា បោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ៖**

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងទន្ទឹមនឹងគណបក្សនយោបាយលើសពីមួយគណបក្ស
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់គណបក្សនយោបាយ ឬមិនចំលេខរៀងនៃគណបក្សនយោបាយណាមួយ ទោះបីជាមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងគណបក្សនយោបាយណាមួយក៏ដោយ។

**ខ.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត៖**

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និង នៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានបិទតែមប្រ៍ ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗភ្ជាប់នៅត្រង់ប្រអប់គណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត។

**ខ.៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច៖**

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់នៃគណបក្សនយោបាយណាមួយ
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរ ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ។

**ខ.៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការ៖**

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ឧទាហរណ៍

ក. គំរូសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ព




ខ. គំរូសន្លឹកឆ្នោតមិនបានការត្រូវបានចាត់ទុកជាមោឃៈ

ខ.១ សន្លឹកឆ្នោតដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ

សន្លឹកឆ្នោតទាំងឡាយណាដែលមិនបានផ្តល់ឱ្យជាផ្លូវការដោយមន្ត្រីការិយាល័យបោះឆ្នោត ឬមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ក្លែងបន្លំ មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ រួមមានៈ




១. សន្លឹកឆ្នោតមានខ្នាតតូចជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.បៗ




២. សន្លឹកឆ្នោតមានខ្នាតធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.បៗ




៣. សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.បៗ




៤. សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការ របស់ គ.ជ.បៗ




៥.សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភានៅតាមមណ្ឌលតូមិភាគពាក់ព័ន្ធៗ




៦ សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពី ចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើស តាំងសមាជិកព្រឹទ្ធសភានៅតាមមណ្ឌលតូមិភាគនីមួយៗៗ







៧. សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់មណ្ឌលភូមិភាគនីមួយៗ

៨. សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ

### ខ.២ សន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូស ដែលពុំអាចសន្និដ្ឋានថា បោះគាំទ្រគណបក្សនយោបាយណាមួយ







១. សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)ៗ

២. សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងទន្ទឹមនឹងគណបក្សនយោបាយលើសពីមួយគណបក្សៗ




៣. សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់គណបក្សនយោបាយ ឬមិនចំលេខរៀងនៃគណបក្សនយោបាយណាមួយ ទោះបីជាមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងគណបក្សនយោបាយណាមួយក៏ដោយ។

ខ.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត




១.សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង។




២. សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង។




៣. សន្លឹកឆ្នោតដែលមានបិទតែមប្រៃ ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗឆ្លាប់នឹងប្រអប់នៃគណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងៗ




៤. សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយៗ




៥. សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោតៗ

## ខ.៤ សន្លឹកឆ្នោតដែលមានរហែក ឬប្រឡាក់ខូច




១. សន្លឹកឆ្នោតរហែក ដាច់បាត់លេខរៀង ឬប្រអប់នៃគណបក្សនយោបាយណាមួយ។




២. សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង។




៣.សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរ ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ។

ខ.៥ សន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ



១.សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ



២. សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ

## ៤. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត

ប្រធាន គ.ក.រ ប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន និងត្រូវចាត់ចែងការងារ ដូចខាងក្រោម៖

### ក. ការរៀបចំសម្ភារ ឯកសារ

ប្រធាន គ.ក.រ ត្រូវ៖

*ដាក់ក្បែរខ្លួន*

- *កញ្ចប់សុវត្ថិភាព «ក»*
- *ទ.១១១៥ សម្រាប់ស្រង់វត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍*
- *ទ.១២០២ សម្រាប់ជូនភ្នាក់ងារគណបក្សនយោបាយ (ប្រសិនបើមានការស្នើសុំ)*
- *ស្បោងប្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ*
- *កៅស៊ូកង។*

| | |
|---|---|
| ឱ្យអនុប្រធាន | តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ច្បាប់។ |
| ឱ្យលេខាធិការ | - ទ.១១០២ ចំនួនគ្រប់គ្រាន់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត<br>- តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ច្បាប់<br>- ស្រោមសំបុត្រដាក់ ទ.១១០១ ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព "ក" និងប្រាប់គាត់ឱ្យបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដែលមានកត់ត្រានៅក្នុង ទ.១១០១។ |
| ឱ្យសមាជិកទី១ | ផ្ទាំងក្រដាសធំ ១ផ្ទាំង និងប៊ិកហ្វឺត ១ដើម សម្រាប់កត់ត្រាសំឡេងឆ្នោត។ |

**ខ. ការពិនិត្យហិបឆ្នោត នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

| | |
|---|---|
| ប្រធាន គ.ក.រ ត្រូវ | - ពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំង២ ដែលចាក់ជាប់គម្របខាងក្រៅនៃហិបឆ្នោតស្ថិតក្នុងស្ថានភាពដើម។<br>- កាត់ផ្តាច់សោឃ្លុំទាំង២ នេះដោយកន្ត្រៃ ឬកូនកាំបិត បើកគម្របខាងក្រៅចេញ។<br>- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់លេខសោឃ្លុំដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្តើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថា គ្មានការរុះរើ។<br>- កាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសបិទពាសនេះចោល។<br>- បើកគម្របខាងក្នុងនៃហិបឆ្នោត។<br>- ចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុ ត្រង់ចន្លោះអនុប្រធាន និងសមាជិកទី១។<br>- ដាក់ហិបឆ្នោតទទេនៅក្បែរខ្លួន។ |

## ការចាក់សន្លឹកឆ្នោតចេញពីហិបឆ្នោត




### គ. ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត

ប្រធាន គ.ក.រ ត្រូវ៖

| | |
|---|---|
| *ឱ្យសមាជិកទី១* | *រើសយកវត្ថុមិនមែនជាសន្លឹកឆ្នោតដែលមិនស្អិតនៅជាប់ជាមួយសន្លឹកឆ្នោត(បើមាន)ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ក្នុងស្រោមសំបុត្រ១ បម្រុងស្រាប់។* |
| *ឱ្យលេខាធិការ* | *កត់ត្រាវត្ថុដែលមិនមែនជាសន្លឹកឆ្នោត (បើមាន) ចូលក្នុង ទ.១១០២។* |
| *ឱ្យអនុប្រធាន និងសមាជិកទី១* | *- លា និងតម្រៀបសន្លឹកឆ្នោតដែលទើបត្រូវបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម។*<br>*- ដាក់សន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ក្នុង ១បាច់មាន ២៥សន្លឹក នៅពំនូកទី១។*<br>*- ដាក់សន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (បើមាន) នៅពំនូកទី២។*<br>*- រាប់ចំនួនសន្លឹកឆ្នោតទាំង ២ពំនូកឱ្យបានត្រឹមត្រូវ។*<br>*- រាយការណ៍ជូនប្រធានអំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ។*<br>*- ហុចសន្លឹកឆ្នោតពំនូកទី២ ដែលគ្មានបោះត្រាសម្ងាត់នៅខាងខ្នង (បើមាន) ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់។*<br>*- ហុចសន្លឹកឆ្នោតពំនូកទី១ ដែលខ្ទាស់ជាបាច់ក្នុង ១បាច់ ២៥សន្លឹក ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់។* |

**ឃ. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត**

**- អនុវត្តតាមរូបមន្តៈ**

| | | |
|---|---|---|
| *ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប* | = | *ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត* |

ឬ

| | | | | |
|---|---|---|---|---|
| *ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប* | = | *ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង* | - | *ចំនួនសន្លឹកឆ្នោតមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច* |

- ប្រសិនបើស្មើគ្នា លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននោះចូលក្នុង ទ.១១០២។
- ប្រសិនបើខុសគ្នា ប្រធានត្រូវផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតឡើងវិញជាលើកទី២ យ៉ាងហ្មត់ចត់។
- ប្រសិនបើនៅតែខុសគ្នាដដែល ប្រធាន គ.ក.រ ត្រូវៈ
    - ចាត់លេខាធិការឱ្យកត់ត្រាតួលេខដែលខុសគ្នានោះចូលក្នុង ទ.១១០២។
    - ប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនោះ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន។

**ង. ការកំណត់សុពលភាព និងការប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ**

ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១សន្លឹកពីពំនូកទី១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មើលឃើញច្បាស់។



- **សន្លឹកឆ្នោតបានការ**

*ប្រធាន គ.ក.រ ត្រូវ*

- *ប្រកាសឱ្យឮៗអំពីគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ។*
- *កាន់បង្ហាញសន្លឹកឆ្នោតផ្នែកខាងមុខ ខាងខ្នងឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចបានឃើញច្បាស់ តែមិនអនុញ្ញាតឱ្យប៉ះពាល់ ឬកាន់សន្លឹកឆ្នោតឡើយ។*
- *ដាក់សន្លឹកឆ្នោតបានការនោះទៅតាមពំនូកដោយឡែកៗ តាមគណបក្សនយោបាយពាក់ព័ន្ធនីមួយៗ។*
- *ចាត់អនុប្រធាន និងលេខាធិការ ឱ្យគូសពិន្ទុ១ សម្រាប់សន្លឹកឆ្នោត១សន្លឹកដែលគណបក្សនយោបាយពាក់ព័ន្ធបានទទួលនៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។*
- *ចាត់សមាជិកទី១ គូសពិន្ទុ១ ដោយប្រើប៊ិកហ្វឺតនៅលើផ្ទាំងក្រដាសធំដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន។*
- *ដាក់សន្លឹកឆ្នោតជំទាស់ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ប្រសិនបើមានការជំទាស់ពីភ្នាក់ងារគណបក្សនយោបាយក្នុងការកំណត់សុពលភាព។*

- **សន្លឹកឆ្នោតមិនបានការ**

*ប្រធាន គ.ក.រ ត្រូវ*

- *កំណត់ និងបញ្ជាក់ហេតុផលថា សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ។*
- *ប្រកាសថាជាសន្លឹកឆ្នោតមិនបានការ។*
- *លើកបង្ហាញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតមិនបានការនោះ។*
- *ដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ។*

**ច. ការកំណត់សុពលភាពចុងក្រោយនូវរាល់សន្លឹកឆ្នោតមិនបានការ**

នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី១ ប្រធាន គ.ក.រ ត្រូវបន្តយកសន្លឹកឆ្នោតម្តង ១សន្លឹកៗពីពំនូកសន្លឹកឆ្នោតមិនបានការមកពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

**ចំណាំ៖**

- ☛ ការកំណត់សុពលភាពសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវអនុវត្តដូចចំណុច «ង» ខាងលើនេះ។
- ☛ ប្រសិនបើ ភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធាន គ.ក.រ ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ៖
    - ▪ ភ្នាក់ងារនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះចូលក្នុង ទ.១១០២។

- ខ្លឹមសារ និងហេតុផលនៃការជំទាស់នោះ មិនត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារនោះ មិនព្រមចុះហត្ថលេខាលើ ទ.១១០២។
- ការសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.រ ត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត។
- ប្រធាន គ.ក.រ ត្រូវផ្តល់ ទ.១២០២ ចំនួន ៣ច្បាប់ ដល់ភ្នាក់ងារគណបក្សនយោបាយ(ប្រសិនបើមានការស្នើសុំ) ដើម្បីប្តឹងទៅ គធ.ខប។

## ៨. ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត

### ក. ការបូកសរុបលទ្ធផល

*ប្រធាន គ.ក.រ ត្រូវ*

- *ឱ្យអនុប្រធាន និងលេខាធិការបូកសរុបលើ ទ.១១០៨។*
- *ឱ្យសមាជិកទី១បូកសរុបលើផ្ទាំងក្រដាសធំ។*

- *ចំនួនសន្លឹកឆ្នោតមិនបានការសរុប។*
- *ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ។*
- *ចំនួនសន្លឹកឆ្នោតបានការសរុប។*
- *ផ្ទៀងផ្ទាត់តួលេខគ្នា។*

*ប្រធាន គ.ក.រ ត្រូវ*

- *រាប់ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ។*
- *រាប់ចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់។*
- *ផ្ទៀងផ្ទាត់តួលេខខាងលើជាមួយតួលេខរបស់អនុប្រធាន លេខាធិការ និងសមាជិកទី១។*
- *បូកសរុបចំនួនសន្លឹកឆ្នោតបានការគ្រប់គណបក្សនយោបាយទាំងអស់។*
- *បូកសរុបបញ្ចូលគ្នាចំនួនសន្លឹកឆ្នោតបានការ និងចំនួនសន្លឹកឆ្នោតមិនបានការ។*

### ខ. រូបមន្តនៃការផ្ទៀងផ្ទាត់

| *ចំនួនសន្លឹកឆ្នោតបានការសរុប + ចំនួនសន្លឹកឆ្នោតមិនបានការសរុប* | = | *ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត* |
|---|---|---|

**- ប្រសិនបើឃើញស្មើគ្នា៖**

- ប្រធាន និងលេខាធិការចុះហត្ថលេខា បោះត្រាលើ ទ.១១០៨ ទាំង ២ច្បាប់។
- ប្រធានប្រកាសជាចំហនូវលទ្ធផលនៃការរាប់សន្លឹកឆ្នោត។
- លេខាធិការកត់ត្រាតួលេខចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ និងសន្លឹកឆ្នោតមិនបានការទាំងអស់ចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

**- ប្រសិនបើឃើញមិនស្មើគ្នា៖**

ករណីផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះមានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងដែលបានរាប់ឃើញ៖

**ប្រធាន គ.ក.រ ត្រូវ**

- *រាប់សន្លឹកឆ្នោតតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត។ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូកឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ នៅតែមានខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើនត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះ ត្រូវសន្មតថា ភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ។*
- *ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះក្នុង ទ.១១០២។*
- *ធានាថា សន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ដោយឡែកពីគ្នា។*
- *ធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្រពោះពុម្ពស្រាប់ ដែលមានកាខ្វង់ថា «សន្លឹកឆ្នោតមិនបានការ»។*

**៦. ការប្រើប្រាស់ ទ.១១០២ ទ.១១០៨ និងការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោងប្លាស្ទិក**

**ក. ការប្រើប្រាស់ ទ.១១០២ និង ទ.១១០៨**

**- ការប្រើប្រាស់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)**

ប្រធាន គ.ក.រ ត្រូវធានាថា កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចំនួន ៥ច្បាប់ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ព្រមទាំងបោះត្រាការិយាល័យបោះឆ្នោត។

ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញ ទ.១១០២ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។ ការមិនព្រមចុះហត្ថលេខាលើ ទ.១១០២ ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។ ទ.១១០២ ត្រូវប្រើប្រាស់ដូចខាងក្រោមៈ

*ទ.១១០២ ចំនួន ៥ច្បាប់*

- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ នៅក្នុងនោះស្រាប់ ហើយត្រូវដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» វិញ ផ្ញើជូន គ.ជ.ប។*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ)។*
- *២ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ១ ដែលមាន ទ.១១០១ ចំនួន១ ច្បាប់ នៅក្នុងនោះស្រាប់ ដើម្បីត្រៀមទុកដាក់ក្នុងស្បោង «ខ» ផ្ញើជូន គធ.ឃប។*
- *១ច្បាប់ ឱ្យសមាជិកទី២ បិទផ្សាយជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។*

**ចំណាំៈ**

☛ ប្រធាន គ.ក.រ ត្រូវចាត់ឱ្យសមាជិក គ.ក.រ ចម្លង ទ.១១០២ សម្រាប់ចែកជូនដល់គ្រប់ភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន និងចាត់ឱ្យសមាជិក

ទី២ យក ទ.១១០២ ចំនួន ១ច្បាប់ រួមជាមួយនឹងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ជូន គធ.ឃប ជាបន្ទាន់នៅល្ងាចនៃថ្ងៃបោះឆ្នោត។

**- ការប្រើប្រាស់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)**

តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ២ច្បាប់ ដែលចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.រ និងបោះត្រា ព្រមទាំងអាចមានការចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយផងនោះ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៨ ចំនួន ២ច្បាប់*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ និង ទ.១១០២ ចំនួន ១ច្បាប់ នៅក្នុងនោះស្រាប់ ហើយត្រូវដាក់ក្នុងកញ្ចប់សុវត្ថិភាព«ក» វិញ ផ្ញើជូន គ.ជ.ប។*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ១ ដែលមាន ទ.១១០១ ចំនួន ១ច្បាប់ និង ទ.១១០២ ចំនួន ២ច្បាប់ ត្រៀមទុកដាក់ក្នុងស្បោង «ខ» ផ្ញើជូន គធ.ឃប។*

**ខ. ការវេចខ្ចប់ស្បោងប្លាស្ទិក**

គ.ក.រ ត្រូវដាក់សម្ភារ ឯកសារក្នុងស្បោងប្លាស្ទិកសម្រាប់ត្រៀមបញ្ជូនទៅ គធ.ឃប។

*សម្ភារ ឯកសារ ដាក់ក្នុងស្បោង ប្លាស្ទិកមាន*
- *សន្លឹកឆ្នោតបានការដែលបានចងនឹងកៅស៊ូកងតាមគណបក្សនយោបាយនីមួយៗ។*
- *ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ។*
- *ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតដែលចុះហត្ថលេខាដោយលេខាធិការ និងប្រធាន និងបោះត្រាការិយាល័យបោះឆ្នោត ព្រមទាំងអាចមានការចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។*
- *ស្រោមសំបុត្រដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោត (បើមាន)។*

*ប្រធាន គ.ក.រ ត្រូវ*
- *ចងភ្ជិតមាត់ស្បោងប្លាស្ទិក។*
- *សរសេរលេខកូដការិយាល័យបោះឆ្នោតដោយប៊ិកហ្វឺតនៅផ្នែកខាងក្រៅនៃស្បោងប្លាស្ទិកដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា « សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ........»។*

## V. ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធ

ការងារនេះត្រូវធ្វើបន្ទាប់ពីការរាប់សន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតរួចរាល់។

*ប្រធាន គ.ក.រ ត្រូវ*
- *អញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួមពិនិត្យមើលដំណើរការនៃការរៀបចំវេចខ្ចប់ និងការបញ្ជូន ព្រមទាំងកត់ត្រាលេខសោឃ្លុំមាត់ស្បោង «ខ»។*
- *ចាត់ចែងសមាជិកដើម្បីអនុវត្តដំណើរការនេះ។*

## ១. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក»

គ.ក.រ ត្រូវៈ

- ដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» នូវៈ
  - ស្រោមសំបុត្រដាក់ ទ.១១០១ ចំនួន ១ច្បាប់ ទ.១១០២ ចំនួន ១ច្បាប់ និង ទ.១១០៨ ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើក្នុងការបោះឆ្នោត
  - ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច»(បើមាន)
  - ស្បោងប្លាស្ទិកដាក់ «សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»
  - ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
  - ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត» (បើមាន)
  - ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (បើមាន)
  - ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន)។
- ផ្ទៀងផ្ទាត់ បិទភ្ជិតដោយការសុវត្ថិភាព បំពេញលេខកូដការិយាល័យបោះឆ្នោតដោយប៊ិកហ្វឺតលុបមិនជ្រះ។

**កញ្ចប់សុវត្ថិភាព «ក»**

| ឃុំ/សង្កាត់ | រាជធានី ខេត្ត | | ការិយាល័យបោះឆ្នោត | | | |
|---|---|---|---|---|---|---|
| | | | | | | |

*- ស្រោមសំបុត្រដាក់ ទ.១១០១ ចំនួន ១ច្បាប់ ទ.១១០២ ចំនួន ១ច្បាប់ និង ទ.១១០៨ ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប។*
*- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។*
*- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច»(បើមាន)។*
*- ស្បោងប្លាស្ទិកដាក់«សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»។*
*- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។*
*- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត» (បើមាន)។*
*- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (បើមាន)។*
*- ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន)។*

## ២. ការវេចខ្ចប់ស្បោង «ខ»

ប្រធាន គ.ក.រ ត្រូវធានាក្នុងការវេចខ្ចប់ស្បោង«ខ»ដើម្បីបញ្ជូនទៅ លគធ.ខប នូវសម្ភារ ឯកសារបោះឆ្នោត ដូចខាងក្រោមៈ

-កញ្ចប់សុវត្ថិភាព «ក»

-ស្រោមសំបុត្រដាក់ ទ.១១០២ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ)

-ស្រោមសំបុត្រដាក់ ទ.១១០១ ចំនួន ១ច្បាប់ ទ.១១០២ ចំនួន ២ច្បាប់ ទ.១១០៨ ចំនួន ១ច្បាប់ និង ទ.១១១៥ ចំនួន ១ច្បាប់ ផ្ញើជូន គឃ.ខប

-ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួល សម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់

-ស្រោមសំបុត្រតូចមួយដាក់ត្រា គ.ក.ប (ដាក់ក្រោយពេលបានបោះត្រាលើ ទ.១១០៧ រួច)។

**ចំណាំ**

☛ ប្រធាន គ.ក.រ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ លគឃ.ខប និងបានកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់ស្បោង «ខ»។ ប្រធាន គ.ក.រ ត្រូវ ៖

- ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោត។

*ទ.១១០៧ ចំនួន៣ច្បាប់*
- *១ច្បាប់ ច្រកចូលស្រោមសំបុត្រ រួចដាក់ចូលក្នុងស្បោង «ខ»*
- *១ច្បាប់ ដាក់ក្នុងហោប៉ៅក្រៅនៃស្បោង «ខ»*
- *១ច្បាប់ ប្រើក្នុងការប្រគល់ ទទួលនៅ លគឃ.ខប។*

- ចងភ្ជិតមាត់ស្បោង«ខ» និងចាក់សោឃ្លុំមានលេខ។
- សរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវដោយប៊ិកហ្វឺតលុបមិនជ្រះ។



៣. ការវេចខ្ចប់សម្ភារ ឯកសារនៅសល់ បញ្ជូនទៅ លគធ.ខប អមជាមួយស្បោង «ខ»

ក. ការរៀបចំវេចខ្ចប់កញ្ចប់សម្ភារ ឯកសារនៅសល់

| | |
|---|---|
| ប្រធាន គ.ក.រ ត្រូវ ចាត់ចែងឱ្យ | - *បត់ហិបឆ្នោតតាមលំនាំដើម និងច្រកក្នុងស្រោមកេសក្រដាស។*<br>- *ដាក់ស្លាកការិយាល័យបោះឆ្នោត និងសម្ភារ ឯកសារនៅសល់ផ្សេងទៀតក្នុងកេសស័ង្កសី។*<br>- *វេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក។*<br>- *បត់បន្ទប់សម្ងាត់តាមផ្នត់ដើម និងច្រកក្នុងការុងនីឡុង។* |

ខ. ការបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចុះហត្ថលេខាដោយប្រធាន គ.ក.រ

*ទ.១១០៧ ចំនួន២ច្បាប់*
- *១ច្បាប់ ដាក់ក្នុងកេសស័ង្កសី ឬកញ្ចប់*
- *១ច្បាប់ ប្រើក្នុងការប្រគល់ ទទួលនៅ លគធ.ខប*

## VI. ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ លគធ.ខប

១. ការបញ្ជូនស្បោង «ខ» និងកញ្ចប់ដាក់សម្ភារនៅសល់ទៅ លគធ.ខប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត

ប្រធាន គ.ក.រ ត្រូវប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលមានវត្តមានឱ្យចូលរួមជាសាក្សីក្នុងការបញ្ជូន និងការប្រគល់ ទទួលស្បោង «ខ» ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលស្បោង «ខ» និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅ លគធ.ខប។

សមាសភាពអ្នកបញ្ជូន៖

- ប្រធាន អនុប្រធាន និងសមាជិក គ.ក.រ តាមការចាំបាច់
- កម្លាំងសន្តិសុខ ២នាក់ (បើចាំបាច់)។

២. ការប្រគល់ ទទួលនៅ លគធ.ខប

នៅពេលប្រគល់ ទទួលស្បោង «ខ» និងកញ្ចប់ដាក់សម្ភារនៅសល់ មន្ត្រី លគធ.ខប ត្រូវពិនិត្យផ្ទៀងផ្ទាត់ និងចាត់ចែងអនុវត្ត ៖

ក. ពេលត្រួតពិនិត្យ

- បើកស្បោង «ខ» ឬ/និងកញ្ចប់ដាក់សម្ភារនៅសល់
- មិនអនុញ្ញាតឱ្យរុះរើកញ្ចប់សុវត្ថិភាព «ក» ឡើយ
- ដកយក ទ.១១០៧ ពីស្បោង «ខ» ចំនួន ១ច្បាប់ ពីក្នុងហោប៉ៅក្រៅស្បោង «ខ» ចំនួន ១ច្បាប់ និងទ.១១០៧ ពីអ្នកប្រគល់
- ដកយក ទ.១១០៧ ពីក្នុងកញ្ចប់ ឬកេសស័ង្កសីដាក់សម្ភារនៅសល់ ចំនួន ១ច្បាប់ និង ទ.១១០៧ ពីអ្នកប្រគល់
- ពិនិត្យផ្ទៀងផ្ទាត់រាល់សម្ភារ ឯកសារក្នុងស្បោង «ខ» ឬ/និងកញ្ចប់ដាក់សម្ភារនៅសល់ ដោយផ្អែកលើ ទ.១១០៧
- ចុះហត្ថលេខាលើ ទ.១១០៧ ទាំង ៣ច្បាប់សម្រាប់ការប្រគល់ ទទួលស្បោង «ខ» និង ២ច្បាប់ទៀតសម្រាប់ការប្រគល់ ទទួលកញ្ចប់ដាក់សម្ភារនៅសល់

និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សីផង។ ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុក ទ.១១០៧ ជាមោឃៈទេ។

*ទ.១១០៧ ចំនួន៣ច្បាប់ (សម្រាប់ស្បោង «ខ»)*
- *១ច្បាប់ ដាក់ក្នុងហោប៉ៅស្បោង «ខ»*
- *១ច្បាប់ ជូនប្រធាន គ.ក.រ*
- *១ច្បាប់ ទុកជាឯកសារនៅ លគធ.ខប*

*ទ.១១០៧ ចំនួន ២ច្បាប់ (សម្រាប់កញ្ចប់ដាក់សម្ភារនៅសល់)*
- *១ច្បាប់ ដាក់ក្នុងកញ្ចប់ដាក់សម្ភារនៅសល់*
- *១ច្បាប់ ជូនប្រធាន គ.ក.រ។*

ខ. ក្រោយពេលត្រួតពិនិត្យ

- កត់ចំណាំរាល់ស្បោង «ខ» និងកញ្ចប់ដាក់សម្ភារនៅសល់ ដោយត្រូវរក្សាទុកនៅកន្លែងមានសុវត្ថិភាព និងដាក់តាមលំដាប់លំដោយនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ
- ចាត់ចែងឱ្យមានកម្លាំងសន្តិសុខយាមការពារ អគារដែលត្រូវរក្សាទុកស្បោង «ខ» និងកញ្ចប់ដាក់សម្ភារនៅសល់។

## VII. ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គធ.ខប

### ១. ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

ភ្នាក់ងារគណបក្សនយោបាយដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការជំទាស់ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយនៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត អាចដាក់ពាក្យបណ្ដឹងទៅ គធ.ខប ជាបន្ទាន់ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅ គធ.ខប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

ក. រយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង

*ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្ដឹងត្រូវ* → *-បំពេញ ទ.១២០២ ចំនួន ៣ច្បាប់*<br>*-ដាក់នៅល្ងាចថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៨ រហូតយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០នាទីព្រឹក ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨* → *ដាក់នៅ គធ.ខប*

**ចំណាំ**

- ក្នុងរយៈពេលកំណត់ខាងលើនេះ បើ គធ.ខប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ គធ.ខប ត្រូវចាត់ទុកថា គ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

**ខ.ព័ត៌មានចាំបាច់មួយចំនួនក្នុងពាក្យបណ្តឹង**

- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។
- កម្មវត្ថុនៃបណ្តឹង។
- ប្រភេទនៃអំពើល្មើស។
- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង និងលក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត។
- បើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ព.ស ឬ ប.ន.ព.ស ដែលត្រូវបានរំលោភ។
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ឬភាពមិនប្រក្រតី។
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (បើមាន)។
- សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត (បើមាន)។
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (បើមាន)។

**គ. ពាក្យបណ្តឹងដែលបានដាក់ក្រោយរយៈពេលកំណត់**

*ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវ*

- *ចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់*
- *ចុះពេលវេលា និងកាលបរិច្ឆេទ ចុះហត្ថលេខា សរសេរឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹងទាំង ៣ច្បាប់*
  - *ទ.១២០២ ចំនួន៣ច្បាប់*
    - *១ច្បាប់ ជូនអ្នកប្តឹងវិញ*
    - *១ច្បាប់ ផ្ញើជូន គ.ជ.ប*
    - *១ច្បាប់ ទុកជាឯកសារ លគធ.ខប។*
- *ប្រាប់អ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។*

### ឃ. ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់

*ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវ*

- *ណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាក្នុងកំណត់ហេតុ*
- *ចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ក្នុងករណីដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងនោះ*
- *ចុះហត្ថលេខា ចុះកាលបរិច្ឆេទ សរសេរឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្ដឹងទាំង ៣ច្បាប់*

*ទ.១២០២ ចំនួន៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាងវិញ*
- *១ច្បាប់ ផ្ញើជូន គ.ជ.ប*
- *១ច្បាប់ ទុកជាឯកសារ លគធ.ខប។*

### ង. ពាក្យបណ្ដឹងដែលបានដាក់ក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់

*ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវ*

- *ធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រា រួចឱ្យអ្នកប្ដឹង ឬតំណាងនោះផ្ដិតមេដៃលើកំណត់ហេតុ។*
- *ចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ*
- *ចុះពេលវេលា កាលបរិច្ឆេទ ចុះហត្ថលេខា សរសេរឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្ដឹងទាំង ៣ច្បាប់*

*ទ.១២០២ ចំនួន ៣ច្បាប់*
- *១ច្បាប់ ប្រគល់ជូនអ្នកប្ដឹងវិញ*
- *១ច្បាប់ បិទផ្សាយជាសាធារណៈនៅ លគធ.ខប*
- *១ច្បាប់ ទុកសម្រាប់ គធ.ខប ប្រើក្នុងពេលប្រជុំសម្រេច។*

- *ជម្រាបអ្នកប្ដឹងថា គធ.ខប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធក្នុងអំឡុងពេលនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងរាជធានី ខេត្ត។*

### ច. ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែល គធ.ខប អាចបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត

ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែលត្រូវបានដាក់ក្នុងរយៈពេលកំណត់ មានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ និងមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គធ.ខប អាចបើកកញ្ចប់

សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។ ក្នុងករណីនេះ ប្រធានក្រុមត្រូវចាត់ចែងអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖

➢ នៅចំពោះមុខដើមបណ្តឹង តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ប្រធានក្រុមត្រូវ ៖
  - បង្គាប់ជំនួយការឱ្យទៅនាំយកស្បោង « ខ » មានបណ្តឹងនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ មកដាក់នៅលើតុចំពីមុខប្រធានក្រុម។
  - ស្រាយមាត់ស្បោង «ខ» នោះ ដកយកកញ្ចប់សុវត្ថិភាព «ក» មកដាក់នៅលើតុ។
  - បើកកញ្ចប់សុវត្ថិភាព «ក» រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុមុខគាត់។
  - ប្រគល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ឱ្យទៅលេខាធិការសម្រាប់តាមដានពិនិត្យ និងប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។
  - បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីពិនិត្យផ្ទៀងផ្ទាត់។

➢ យកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និងបញ្ហាជារួម ដូចខាងក្រោម៖
  - ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត។
  - ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់ ដែលប្រើសម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។
  - ពិនិត្យនិងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត។
  - ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ។
  - រាប់ចំនួនសន្លឹកឆ្នោតខូច (បើមាន)។
  - រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ។
  - ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ។
  - ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ។
  - ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ចំនួន ២ច្បាប់ ដោយលើកយោបល់ស្នើសុំ គជ.ខប ពិនិត្យសម្រេច ៖
    - យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ
    - ស្នើសុំ គ.ជ.ប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ របាយការណ៍ទាំង ២ច្បាប់ ដែលត្រូវចុះហត្ថលេខា ដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល។

- របាយការណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ចំនួន ១ច្បាប់ ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធដែលក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គធ.ឃប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យសម្រេច។

*របាយការណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ចំនួន ២ច្បាប់*
*- ១ច្បាប់ គធ.ឃប ប្រើក្នុងការដោះស្រាយពាក្យបណ្ដឹង និងទុកជាឯកសារ*
*- ១ច្បាប់ ផ្ញើជូន គ.ជ.ប*

- ចាត់ចែងវេចខ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព «ក» វិញតាមលំនាំដើម និងចងភ្ជិតកញ្ចប់សុវត្ថិភាព «ក» នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។
- ដាក់កញ្ចប់សុវត្ថិភាព «ក» ទៅក្នុងស្បោង «ខ» រួចចងភ្ជិត និងចាក់សោឃ្លុំមានលេខ រួចដាក់ស្បោង «ខ» កន្លែងដើម ត្រៀមវេចខ្ចប់ដាក់ក្នុងស្បោង «ឃ»។

**២. ការដោះស្រាយរបស់ គធ.ឃប លើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

- ផ្អែកលើរបាយកាណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល
- ផ្អែកលើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែល គធ.ឃប បានទទួល
- គធ.ឃប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធនោះ ដោយធ្វើកំណត់ហេតុផង។ ក្នុងករណី គធ.ឃប សម្រេច៖
  - បដិសេធលើពាក្យបណ្ដឹង គធ.ឃប ត្រូវចារយល់ព្រមលើរបាយកាណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល ឬ
  - យល់ព្រមតាមពាក្យបណ្ដឹង គធ.ឃប ត្រូវចារព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត លើរបាយកាណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងលើកសំណើទៅ គ.ជ.ប សុំព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

**ក. ករណី គធ.ឃប សម្រេចបដិសេធពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់**

- ចារយល់ព្រមលើរបាយកាណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព«ក»ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ឃប ព្រមទាំងដាក់បង្ហាញចំពោះអ្នកប្ដឹង ភ្នាក់ងារគណបក្សនយបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។
- ចាត់មន្ត្រី លគធ.ឃប ឱ្យបំពេញ ទ.១២០៣ យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ និងត្រូវបដិសេធពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលបានដាក់នៅ គធ.ឃប ដោយ

បញ្ជាក់ច្បាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រី លគធ.ឌប និងប្រធាន គធ.ឌប ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ឌប។

*ទ.១២០៣ ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង*
- *១ច្បាប់ ផ្ញើជូន គ.ជ.ប*
- *១ច្បាប់ ទុកជាឯកសារនៅ លគធ.ឌប។*

- ជម្រាបអ្នកប្ដឹងថា គាត់មានសិទ្ធិដាក់ពាក្យបណ្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ឌប ទៅ គ.ជ.ប ក្នុងរយៈពេល ២ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- ប្រគល់ ទ.១២០២ ចំនួន ៣ច្បាប់ ជូនអ្នកប្ដឹង (ប្រសិនបើមានការស្នើសុំ)។
- ប្រគល់របាយការណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដែលបានចារ ហើយចំនួន ១ច្បាប់ និង ទ.១២០៣ ចំនួន ១ច្បាប់ ឱ្យទៅក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតទុកជាឯកសារនៅ លគធ.ឌប។

**ខ. ករណី គធ.ឌប សម្រេចយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់**

- ចារព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត លើរបាយការណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព«ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលដែលបានដាក់ជូន គធ.ឌប ពិនិត្យសម្រេច រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ឌប ព្រមទាំងដាក់បង្ហាញចំពោះអ្នកប្ដឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។
- ចាត់មន្ត្រី លគធ.ឌប ឱ្យបំពេញ ទ.១២០៣ យល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយដែលត្រូវចុះហត្ថលេខាដោយមន្ត្រី លគធ.ឌប និងប្រធាន គធ.ឌប ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ឌប។

*ទ.១២០៣ ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង*
- *១ច្បាប់ ផ្ញើជូន គ.ជ.ប*
- *១ច្បាប់ ទុកជាឯកសារនៅ លគធ.ឌប។*

- ជម្រាបអ្នកប្ដឹងថា គធ.ឌប នឹងលើកសំណើពាក់ព័ន្ធនឹងករណីសុំព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ ព្រមទាំងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដោយឡែក និងបញ្ជូនទៅ គ.ជ.ប ក្នុងរយៈពេល ២៤ម៉ោងយ៉ាងយូរ បន្ទាប់ពី គធ.ឌប សម្រេចយល់ព្រមតាមពាក្យបណ្ដឹង ដើម្បី គ.ជ.ប ពិនិត្យសម្រេច។
- ប្រគល់របាយការណ៍ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដែលបានចារ ហើយចំនួន ១ច្បាប់ និង ទ.១២០៣ ចំនួន ១ច្បាប់ ឱ្យទៅក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតទុកជាឯកសារនៅ លគធ.ឌប។

## VIII. កិច្ចប្រតិបត្តិការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ត្រូវ៖

- ធ្វើបន្ទាប់ពីបានទទួលស្បោង «ខ» ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត។
- ធ្វើនៅ លគធ.ខប និងត្រូវឱ្យមានបរិវេណសន្តិសុខដែលមានសុវត្ថិភាពល្អ។
- ប្រសិនបើចាប់ដំណើរការហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយមិនត្រូវឈប់សម្រាកឡើយ។
- ឱ្យមានភ្នាក់ងារគណបក្សនយោបាយ ១នាក់ ក្នុងគណបក្សនយោបាយនីមួយៗ និងអ្នកសង្កេតការណ៍ ១នាក់ក្នុងអង្គការនីមួយៗ។
- ធានាថា ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើលដំណើរការនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួនបាន។

### ១. សមាសភាពនៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

- សមាសភាពនៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវចាត់តាំងពីក្នុងចំណោមសមាជិក គធ.ខប និងមន្ត្រី លគធ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹក។
- សមាសភាពក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប ត្រូវមាន ៤រូប ដឹកនាំដោយប្រធាន ១រូប ដែលជាសមាជិក គធ.ខប ឬមន្ត្រី លគធ.ខប និងមានអនុប្រធាន ១រូប លេខាធិការ ១រូប និងជំនួយការ ១រូប។
- ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គធ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។

### ២. បន្ទប់សម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់បន្ទប់ការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវមានសម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ។

### ៣. កិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

គធ.ខប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តបញ្ចូលគ្នា ឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន ទាំងការិយាល័យគ្មានពាក្យបណ្តឹង ទាំងការិយាល័យមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ (ទោះបី គធ.ខប បើកកញ្ចប់សុវត្ថិភាព «ក» ក៏ដោយ ឬបានសម្រេចយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតណាមួយ

និងលើកសំណើសុំ គ.ជ.ប ពិនិត្យសម្រេចឲ្យជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះក៏ដោយ)។

**ក. សម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទសម្រាប់ក្រុមត្រួតពិនិត្យ**

ប្រធានក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវរៀបចំ និងចាត់ចែងឱ្យមានសម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់ប្រគល់ជូនក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត មានដូចខាងក្រោម ៖

| | |
|---|---|
| *ទុកលើតុមុខគាត់* | - *ទ.១២០២ សម្រាប់ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយ (ប្រសិនបើមានការស្នើសុំ)។*<br>- *សម្ភារ ឯកសារផ្សេងទៀត។*<br>- *ម៉ាស៊ីនគិតលេខ ១គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផល។* |
| *ជូនអនុប្រធាន* | *តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ១ច្បាប់។* |
| *ជូនលេខាធិការ* | - *កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុង រាជធានី ខេត្ត (ទ.១១១១) ចំនួន ១ច្បាប់ ។*<br>- *ទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។* |
| *ជូនជំនួយការ* | *តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត(ទ.១១១០) ចំនួន ១ច្បាប់។* |

**ខ.ការត្រួតពិនិត្យ និងបូកសរុបលទ្ធផល ក្នុងករណីគ្មានពាក្យបណ្ដឹងតវ៉ា និងពាក្យបណ្ដឹងជំទាស់ ឬមានពាក្យបណ្ដឹងតវ៉ា និងពាក្យបណ្ដឹងជំទាស់ដែលបានដាក់ក្រោយរយៈពេលកំណត់ ឬមានពាក្យបណ្ដឹងតវ៉ា និងពាក្យបណ្ដឹងជំទាស់ ដែលគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះទេ**

ក្នុងករណីនេះ គធ.ខប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ឱ្យត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ចំណុះរាជធានី ខេត្ត បញ្ចូលគ្នា ដូចខាងក្រោម៖

- មិនអាចបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតបានឡើយ។

- គ្រាន់តែត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨) ប៉ុណ្ណោះ។

**ប្រធានក្រុមត្រូវ**

- *បង្គាប់ជំនួយការឱ្យនាំយកស្បោង«ខ» ដែលដាក់ ទ.១១០១ និងទ.១១០២ ម្ដងមួយៗពីកន្លែងរក្សាទុក មកដាក់នៅលើតុចំមុខគាត់*
- *ស្រាយមាត់ស្បោង«ខ»រួចដកយកស្រោមសំបុត្រដាក់ ទ.១១០១ ទ.១១០២ និង ទ.១១០៨ ផ្ញើជូន គធ.ខប ដាក់នៅលើតុ*
- *បន្ទាប់មកដកយក ទ.១១០២ ចំនួន ១ច្បាប់ ក្នុងចំណោម ២ច្បាប់ ដែលមានក្នុងស្រោមសំបុត្រនោះ និងប្រគល់ឱ្យជំនួយការ យកទៅបិទផ្សាយនៅខាងមុខ លគធ.ខប។*
- *ដកយកស្រោមសំបុត្រដាក់ ទ.១១០២ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ពីក្នុងស្បោង «ខ» ដាក់ទៅក្នុងកញ្ចប់ «យ ពិសេស» ដែលត្រៀមបម្រុងជាស្រេចនៅក្បែរខ្លួន*
- *រក្សាទុកស្បោង «ខ» នៅក្បែរខ្លួនគាត់។*

➢ **ពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់**

**ប្រធានក្រុមត្រូវ**

- *ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុង ទ.១១០១ និង ទ.១១០៨ នៃការិយាល័យបោះឆ្នោតនីមួយៗ*
- *ប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខក្នុង ទ.១១០២ ពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុង ទ.១១០២ ពិតជាត្រឹមត្រូវមែន ឬ គ.ក.រ មានកំហុសក្នុងការគណនាលេខណាមួយ។*
- *កែតម្រូវតួលេខនោះដោយគូសឆូតលើតួលេខដែលខុស តែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមនោះទេ រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ខ្លួនផង ក្នុងករណី គ.ក.រ មានកំហុសក្នុងការគណនាលេខ។*
- *ចាត់ឱ្យលេខាធិការកត់ត្រាបញ្ហានេះ នៅក្នុងទ.១១១១។*

➢ ពេលបូកសរុបលទ្ធផល

ប្រធានក្រុមត្រូវ

- ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការដែលគាំទ្រគណបក្សនយោបាយនីមួយៗ សន្លឹកឆ្នោតមិនបានការ ទិន្នន័យ និងតួលេខពាក់ព័ន្ធផ្សេងទៀត ដែលបានពិនិត្យត្រឹមត្រូវហើយ ពីក្នុង ទ.១១០២ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- ណែនាំអនុប្រធានក្រុមឱ្យកត់ត្រាតួលេខទាំងនេះ ទៅក្នុង ទ.១១១០ រួចឱ្យគណនាសរុបតួលេខដែលបានកត់ត្រាក្នុងទ.១១១០ (ធ្វើប្រមាណវិធីដោយដៃ និងប្រើម៉ាស៊ីនគិតលេខផង) ហើយផ្ទៀងផ្ទាត់គ្នា។
- ណែនាំលេខាធិការឱ្យស្រង់ ឬ/និងបូកសរុប រួចកត់ត្រាតួលេខ ឬ/និងទិន្នន័យពាក់ព័ន្ធ ដែលក្នុងនោះ រួមមានទាំងចំនួនសរុបនៃសន្លឹកឆ្នោតបានការដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការដែលបានគណនា និងពិនិត្យ ផ្ទៀងផ្ទាត់ត្រឹមត្រូវហើយពី ទ.១១០១ ទ.១១០២ និង ទ.១១១០ បញ្ចូលទៅក្នុង ទ.១១១១ រួចហើយចម្លងតួលេខលទ្ធផលពី ទ.១១១១ បញ្ចូលទៅក្នុង ទ.១១១៤ និងផ្ទៀងផ្ទាត់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត រវាង ទ.១១១៤ និង ទ.១១១០ ក្នុងប្រព័ន្ធកុំព្យូទ័រ។

➢ ក្រោយពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផល

ប្រធានក្រុមត្រូវ

- តែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ នូវ ទ.១១០១ ទ.១១០២ ទ.១១០៨ និងទុកជាឯកសាររបស់ គធ.ខប។
- ចាត់ចែងជំនួយការឱ្យវេចខ្ចប់ស្បោង "ខ" ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព "ក" និងស្រោមសំបុត្រដាក់ត្រា គ.ក.ប ដោយចងភ្ជិត និងចាក់សោឃ្លុំមានលេខ នៅចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ បន្ទាប់មកឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

គ. ការត្រួតពិនិត្យ និងបូកសរុបលទ្ធផល ក្នុងករណី គធ.ខប សម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យណាមួយ និងលើកសំណើទៅ គ.ជ.ប សុំព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ

ក្នុងករណីនេះ ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក៏ត្រូវធ្វើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យ

បោះឆ្នោតនោះទៅក្នុងកំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ផងដែរ។

ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវអនុវត្តតាមករណីគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប ឬមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែរ ប៉ុន្តែពាក្យបណ្ដឹងនោះគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត (*អនុវត្តតាមចំណុច ខ ខាងលើ*)។

**ឃ. ការប្រើប្រាស់ ទ.១១១០ ទ.១១១១ និងក្រដាសលទ្ធផល (ទ.១១១៤)**

➢ **តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០)**

ទ.១១១០ ដែលបំពេញដោយដៃចំនួន ២ច្បាប់ ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និង ទ.១១១០ ពីក្នុងកុំព្យូទ័រចំនួន ៣ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ ត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវចុះហត្ថលេខា ការបរិច្ឆេទ និងបោះត្រា គធ.ខប ដោយអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍។ ប្រធាន គធ.ខប ត្រូវចាត់ចែងប្រើប្រាស់ ទ.១១១០ ដូចខាងក្រោម៖

| | |
|---|---|
| *ទ.១១១០ ចំនួន ៣ច្បាប់* | *- ២ច្បាប់ ដាក់ក្នុងស្រោមសំបុត្រផ្ញើជូន គ.ជ.ប។*<br>*- ១ច្បាប់ រក្សាទុកជាឯកសារ លគធ.ខប។* |

ធានាថា ទ.១១១០ ក្នុងប្រព័ន្ធកុំព្យូទ័រត្រូវបានបញ្ជូនតាមរយៈអ៊ីមែលជាបន្ទាន់មក គ.ជ.ប តាមអាសយដ្ឋានអ៊ីមែលតែមួយគត់ដែលបានកំណត់។

➢ **កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១)**

ទ.១១១១ ចំនួន ៣ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ ត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ដោយអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ។ ប្រធាន គធ.ខប ត្រូវចាត់ចែងប្រើប្រាស់ ទ.១១១១ ដូចខាងក្រោម៖

| | |
|---|---|
| *ទ.១១១១ ចំនួន ៣ច្បាប់* | *-១ច្បាប់ បិទផ្សាយនៅ លគធ.ខប នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដោយត្រូវធ្វើកំណត់ហេតុស្ដីពីការបិទផ្សាយនេះផង។*<br>*-១ច្បាប់ ដាក់ក្នុងស្រោមសំបុត្រផ្ញើជូន គ.ជ.ប ដោយភ្ជាប់ទៅជាមួយនូវកំណត់ហេតុស្ដីពីការបិទផ្សាយ ១ច្បាប់ផង។*<br>*-១ច្បាប់ និងកំណត់ហេតុស្ដីពីការបិទផ្សាយ ១ច្បាប់ទុកជាឯកសារ លគធ.ខប។* |

➢ ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤)

ទ.១១១៤ ចំនួន ៣ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួច ហើយ និងបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និង បោះត្រា គធ.ខប ដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នក សង្កេតការណ៍ ដើម្បីពិនិត្យ។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់ ទ.១១១៤ ដូចខាងក្រោម៖

*ទ.១១១៤ ចំនួន ៣ច្បាប់*
- *-១ច្បាប់ បិទផ្សាយនៅ លគធ.ខប នៅពេល ល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។*
- *-១ច្បាប់ ដាក់ក្នុងស្រោមសំបុត្រផ្ញើជូន គ.ជ.ប។*
- *-១ច្បាប់ រក្សាទុកជាឯកសារនៅ លគធ.ខប។*

**ចំណាំ**

- ប្រធាន គធ.ខប ត្រូវធានាថា ទ.១១១០ ទ.១១១១ និង ទ.១១១៤ ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ។
- ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អាចស្នើសុំថតចម្លងតារាងបូកសរុប លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផល នៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤)។
- ប្រធាន គធ.ខប ត្រូវធានាថា ទ.១១១០ ទ.១១១១ និង ទ.១១១៤ ត្រូវបានដាក់ក្នុង ស្រោមសំបុត្រធំតែមួយ ត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប។

## IX. ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និង រាល់សម្ភារ ឯកសារបោះឆ្នោត ទៅ គ.ជ.ប

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីក្នុងការត្រួតពិនិត្យ និងបូកសរុប លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត រួចរាល់ហើយ គធ.ខប ត្រូវធ្វើការវេចខ្ចប់ ស្បោង «ខ» ដាក់រាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតក្នុង រាជធានី ខេត្ត ទៅក្នុងកញ្ចប់ «ឃ ពិសេស» ស្បោង «ឃ» បញ្ជូន និងប្រគល់ជូន គ.ជ.ប ឱ្យទាន់ពេលវេលា នៅថ្ងៃទីពីរបន្ទាប់ពីថ្ងៃបោះឆ្នោត ដូចខាងក្រោម ៖

**១. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស»**

ក. សម្ភារ ឯកសារដាក់ក្នុងកញ្ចប់ «ឃ ពិសេស» មាន ៖

- រាល់ស្រោមសំបុត្រតែមួយដែលដាក់ ទ.១១១០ ចំនួន ១ច្បាប់ ទ.១១១១ ចំនួន ១ច្បាប់ និង ទ.១១១៤ ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប។
- ស្រោមសំបុត្រដាក់ ទ.១១០២ ដែលដកចេញពីស្បោង «ខ» ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ)
- រាល់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដែលមានការស្នើសុំ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ (បើមាន)។
- រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និង កាខ្នងផ្ញើជូន គ.ជ.ប។
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ច្បាប់។

**ខ. ការបំពេញ ទ.១១០៧**

ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ដោយមានសរសេរវាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងកញ្ចប់«ឃ ពិសេស» និងប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងកញ្ចប់ «ឃ ពិសេស»*
- *១ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់«ឃ ពិសេស»*
- *១ច្បាប់ ប្រើក្នុងការប្រគល់ ទទួល នៅ គ.ជ.ប។*

**គ. ការផ្ទៀងផ្ទាត់ ការបិទន្និតកញ្ចប់ «ឃ ពិសេស» និងសរសេរសម្គាល់**

ប្រធាន គធ.ខប ត្រូវ៖
- ផ្ទៀងផ្ទាត់ឡើងវិញឱ្យបានត្រឹមត្រូវ
- បិទភ្ជិតកញ្ចប់ «ឃ ពិសេស»
- សរសេរសម្គាល់លេខកូដរាជធានី ខេត្តរបស់ខ្លួននៅលើផ្នែកខាងក្រៅនៃកញ្ចប់ «ឃ ពិសេស» ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ។

## កញ្ចប់ «ឃ ពិសេស»

## ដាក់កំណាត់ហេតុបូកសរុបលទ្ធផលនៃបោះឆ្នោតក្នុងរាជធានី ខេត្ត

## រាជធានី ខេត្ត............... ចំណុះមណ្ឌលបោះឆ្នោតទី...............

- រាល់ស្រោមសំបុត្រតែមួយដែលដាក់ ទ.១១១០ ចំនួន ១ច្បាប់ ទ.១១១១ ចំនួន ១ច្បាប់ និង ទ.១១១៤ ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់ ទ.១១០២ ដែលដកចេញពីស្បោង «ខ» ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ)
- រាល់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដែលមានការស្នើសុំ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ (បើមាន)
- រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និងកាខ្ទងផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ច្បាប់។

ទ.១១០៧ ចំនួន ១ច្បាប់

### ២. ការវេចខ្ចប់ស្បោង «ឃ» ព្យួរលទ្ធផលជាបណ្តោះអាសន្ន

ចំពោះរាជធានី ខេត្ត ដែលមានការិយាល័យលើសពីមួយ ហើយ គធ.ខប នៃរាជធានី ខេត្តនោះ បានលើកសំណើព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ប្រធាន គធ.ខប នោះ ត្រូវវេចខ្ចប់សម្ភារ ឯកសារនៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដោយឡែកដាក់ក្នុងស្បោង «ឃ» សុំព្យួរលទ្ធផល។

➢ **សម្ភារ ឯកសារដាក់ក្នុងស្រោមសំបុត្រធំមួយមាន ៖**
  - របាយការណ៍ស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល។
  - សម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្តឹង ដែលត្រូវលើកស្នើ គ.ជ.ប ពិនិត្យសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។

➢ **ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ឃ» ព្យួរលទ្ធផលជាបណ្តោះអាសន្នមាន ៖**
  - ដាក់ស្បោង «ខ» នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលលទ្ធផលនៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវបានលើកសំណើព្យួរជាបណ្តោះអាសន្ន។
  - ស្រោមសំបុត្រធំ ដាក់ឯកសារបោះឆ្នោត(ស្រោមសំបុត្រធំក្នុងចំណុច«**ក**»ខាងលើ)។
  - ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ច្បាប់។

➢ **ការបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)**

ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ដោយមានសរសេររាយ

មុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង «ឃ» សុំព្យួរលទ្ធផល និងប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ឃ» សុំព្យួរលទ្ធផល។*
- *១ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង «ឃ» សុំព្យួរលទ្ធផល។*
- *១ច្បាប់ ប្រើក្នុងការប្រគល់ទទួល នៅ គ.ជ.ប។*

➢ **ការផ្ទៀងផ្ទាត់ ចងភ្ជិតស្បោង «ឃ» និងសរសេរសម្គាល់**

ប្រធាន គធ.ខប ត្រូវ៖
- ផ្ទៀងផ្ទាត់ឡើងវិញឱ្យបានត្រឹមត្រូវ
- ចងភ្ជិតស្បោង «ឃ» សុំព្យួរលទ្ធផល និងចាក់សោឃ្លុំមានលេខ
- សរសេរសម្គាល់ខាងក្រៅនៃស្បោង «ឃ» សុំព្យួរលទ្ធផល ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដរាជធានី ខេត្តពាក់ព័ន្ធ លេខកូដការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។



➢ **ការបញ្ជូនស្បោង «ឃ» សុំព្យួរលទ្ធផលជាបណ្ដោះអាសន្ន**

គធ.ឧប ត្រូវបញ្ជូនស្បោង «ឃ» សុំព្យួរលទ្ធផលជាបណ្ដោះអាសន្នទៅ គ.ជ.ប ក្នុងរយៈពេល ២៤ម៉ោងយ៉ាងយូរបន្ទាប់ពី គធ.ឧប បានចេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្ដឹង ដោយលើកស្នើ គ.ជ.ប ពិនិត្យសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។

**៣.ការវេចខ្ចប់ស្បោង «ឃ» យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត**

ចំពោះការិយាល័យផ្សេងទៀតក្នុងរាជធានី ខេត្តដែលទោះបីមាន ឬគ្មានពាក្យបណ្ដឹងក៏ដោយ ក៏ប៉ុន្តែត្រូវបាន គធ.ឧប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ឬទាំងនោះ ប្រធាន គធ.ឧប ត្រូវ ៖

- ចាត់ចែងវេចខ្ចប់ស្បោង «ខ» ផ្ទុកកញ្ចប់សុវត្ថិភាព «ក» និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោង «ឃ»។
- ចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ដោយមានសរសេររាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង «ឃ» និងប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់*
- *១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង«ឃ»*
- *១ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង«ឃ»*
- *១ច្បាប់ ប្រើក្នុងការប្រគល់ ទទួល នៅ គ.ជ.ប។*

➢ **ការផ្ទៀងផ្ទាត់ ចងខ្សិតស្បោង «ឃ» និងការសរសេរសម្គាល់**

ប្រធាន គធ.ឧប ត្រូវ៖

- ផ្ទៀងផ្ទាត់ឡើងវិញឱ្យបានត្រឹមត្រូវ
- ចងខ្សិតស្បោង «ឃ» យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត និងចាក់សោឃ្លុំមានលេខ
- សរសេរសម្គាល់ខាងក្រៅនៃស្បោង «ឃ» យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដរាជធានី ខេត្តពាក់ព័ន្ធ
- បើស្បោង «ឃ» លើសពីមួយ ឧទាហរណ៍ «ឃ» សរុបមានចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀងថា ១/៣ ២/៣ និង ៣/៣។




## ៤. ការវេចខ្ចប់កញ្ចប់សន្លឹកឆ្នោតបម្រុងដោយឡែក

សន្លឹកឆ្នោតបម្រុងនៅ គធ.ខប ដែលនៅសល់ត្រូវតែបានវេចខ្ចប់ដោយឡែក និងបញ្ជូនមក គ.ជ.ប ដោយបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ និងប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់* {
*-២ច្បាប់ ដាក់ក្នុងកញ្ចប់សន្លឹកឆ្នោតបម្រុង*
*- ១ច្បាប់ ប្រើក្នុងការប្រគល់ ទទួល នៅគ.ជ.ប។*

## ៥. ការវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់

ប្រធាន គធ.ខប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលបានទទួលពី គ.ក.ប ចំណុះរាជធានី ខេត្ត ឬ/និងមាននៅ លគធ.ខប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនដោយឡែកទៅ គ.ជ.ប នៅពេលក្រោយ ដោយបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ និងប្រើប្រាស់ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់* {
*- ២ច្បាប់ ដាក់ក្នុងកេស ឬកញ្ចប់។*
*- ១ច្បាប់ ប្រើក្នុងការប្រគល់ ទទួល នៅគ.ជ.ប។*

## ៦. ការបញ្ជូនទៅ គ.ជ.ប

ការបញ្ជូន និងការប្រគល់ ទទួលកញ្ចប់ «ឃ ពិសេស» និងរាល់ស្បោង «ឃ» និងកញ្ចប់ដាក់សន្លឹកឆ្នោតបម្រុង ត្រូវធ្វើនៅពេលតែមួយព្រមគ្នា គឺនៅថ្ងៃទី២ បន្ទាប់ពីថ្ងៃបោះឆ្នោត។

បោះពុម្ពដោយ គ.ជ.ប

ឆ្នាំ២០១៨